សមាគមបុគ្គលិកសិក្សាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សំភារៈ

២៧

# ទស្សនាវដ្ដី គ្រូបង្រៀន



ខែមេសា-ឧសភា-មិថុនា ឆ្នាំ ២០០៦
ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤-០១១ ៨៨៣ ៩៨៨

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | ជូនពរឆ្នាំថ្មី | ១ |
| | **រាជកិច្ច** | |
| ២ | សេចក្ដីសម្រេចស្ដីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រង... | ២ |
| ៣ | វិចារណកថា | ៥ |
| | **ចប្បធម៌ទូទៅ** | |
| ៤ | ទំនៀមទំលាប់ប្រពៃណីខ្មែរ ស្ដីពីការអប់រំចរិយាសម្បត្តិ (ត) | ៦ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៥ | សិល្បៈនៃការនិយាយក្នុងថ្នាក់រៀន | ១០ |
| | **វិទ្យាសាស្ត្រ និងពត៌មានវិទ្យា** | |
| ៦ | តើយើងអាចបំបាត់ជំងឺស៊ីដា SIDA នាពេលអនាគតដ៏ឆាប់បានរឺទេ? | ១៣ |
| | **ការអប់រំ និងគរុកោសល្យ** | |
| ៧ | ការអប់រំ | ១៦ |
| ៨ | ការណែនាំគរុកោសល្យ (តចប់) | ១៩ |
| ៩ | វិធីបង្រៀន និងកម្មវិធីសៀវភៅសិក្សាភាសាខ្មែរនៅបឋមសិក្សាបំពេញវិជ្ជាពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៧០ (ត) | ២៣ |
| ១០ | កំណែលំអសាលារៀន : ជំហានដំបូងមួយ (ត) | ២៦ |
| ១១ | ការបង្រៀនវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សា និងបឋមសិក្សាជំហានដំបូង | ៣១ |
| ១២ | សិក្សាសង្គម : ចំណីអាហារ | ៣៤ |
| ១៣ | គំនូរ : វិធីបង្រៀនគំនូរ (ត) | ៣៥ |
| ១៤ | ភាសា : ព្យាង្គតំរួតសម័យខេមរយានកម្ម | ៣៨ |
| | **នាទីកំណាព្យ និង កំសាន្ត** | |
| ១៥ | គ្រូត្រូវតែល្អ ក្រត្រូវតែស៊ូ | ៤២ |
| ១៦ | គំរបមិនជ្រាបទឹក | ៤៣ |
| ១៧ | វេទិកាស្ត្រី | ៤៤ |
| | **ពត៌មាន** | |
| ១៨ | តើលោកគ្រូ អ្នកគ្រូ ដឹងទេ...? | ៤៦ |
| ១៩ | ស្ថិតិសពខែមករា-កុម្ភៈ-មីនា ឆ្នាំ២០០៦ | ៤៧ |



**គណៈកម្មការរៀបរៀង និង និពន្ធ**

- លោក កែវ យ៉ារ
- លោក ជុំ ហ៊ីន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ ទិត្យ
- លោកជំទាវ ប៉ែន ណាវុល
- លោក ថោង បូរ៉ាន់
- លោក កៅ ជឿន
- លោកស្រី ប្រាក់ សូលីដា
- លោកស្រី ធន់ សុភ្ញុំ
- លោក ប៉ែន សារុណ
- សមាជិក-សមាជិកាស.ប.ស.ខ

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អ៊ាង
- លោកជំទាវ ហួរ សីរី
- លោក ស៊ុង វ៉ាន់ថន
- លោកបណ្ឌិត អ៊ឹម កុច
- លោក សួង សារុន
- លោក ស៊ិន ស៊ីម

**វិចិត្រករ**

លោក ប៉ាន់ ត្រា

**ការីកុំព្យូទ័រ**

កញ្ញា ម៉ៃ សូនី

**គ្របខាងក្រៅ**

- **ពីមុខ:** សាលាបឋមសិក្សាមួយនៅស្រុកអង្គរជុំ ។
- **ពីក្រោយ:** ព្រះរាជទីនាំង ។



**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

ភ្នំពេញ : ០១២ ៨៩៧ ១៧៧, កំពត : ០១២ ៨៥៦ ៧២២, ក្រុងព្រះសីហនុ : ០១២ ៦៥៩ ៥៦០

សៀមរាប : ០៦៣ ៧៦០ ២១៣ / ០១១ ៨៥៧ ០៩៦ / ០១២ ៦៧៥ ៦៤០



# ជូនពរឆ្នាំថ្មី

## ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំ ច អដ្ឋស័ក

## ព.ស. ២៥៥០

## គណៈកម្មាធិការនាយក ស.ប.ស.ខ.

សូមប្រសិទ្ធពរជ័យ សិរីមង្គលវិបុលសុខ មហាប្រសើរ ជូនចំពោះសមាជិក សមាជិកានៃសមាគមបុគ្គលិកសិក្សាខ្មែរទូទាំងប្រទេស សូមមានសុខភាពល្អបរិបូណ៌ អាយុយឺនយូរ និងពលានុភាពខ្លាំងក្លា ដើម្បីអភិវឌ្ឍការងារអប់រំ និងការងារសមាគមអោយបានរីកចំរើនរុងរឿងតរៀងទៅ ។

ជ.គណៈកម្មាធិការនាយក

ប្រធាន

យស់ អ៊ាង

# រាជកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៥២ សសរ

## សេចក្តីសម្រេច

### ស្តីពី

### ការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយតាមនាទីជាន់ខ្ពស់សំរាប់មន្ត្រីរាជការស៊ីវិល

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុម

ប្រឹក្សាកំណែទម្រង់រដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញសេចក្តីសំរេចលេខ២៤៥សសរ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គមសំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## សម្រេច

ប្រការ១

សេចក្តីសំរេចនេះ មានគោលដៅកែសំរួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសំរាប់មន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព និងសំរាលកូន ដែលបានកំណត់ក្នុងសេចក្តីសំរេចលេខ២៤៥សសរ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គមសំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម ។

ប្រការ២

ត្រូវបានឧបត្ថម្ភជាថវិកា ដើម្បីរួមចំណែក និងជួយដល់គ្រួសារសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព សំរាប់ធ្វើពិធីបុណ្យតាមប្រពៃណី ក្នុងម្នាក់ៗដូចខាងក្រោម:

- ទទួលមរណភាពដោយជំងឺធម្មតា ចំនួន ១ ២០០ ០០០រៀល ( មួយលានពីរសែនរៀល)
- ទទួលមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារចំនួន ១ ៥០០ ០០០រៀល ( មួយលានប្រាំ សែនរៀល)

ប្រការ៣

មន្ត្រីរាជការស៊ីវិលជាស្ត្រីភេទដែលសំរាលកូន និងសំរាកលំហែមាតុភាព ត្រូវបានទទួលថវិកាឧបត្ថម្ភក្នុងម្នាក់ៗចំនួន ៦០០ ០០០រៀល ( ប្រាំមួយរយពាន់រៀល) ។

ប្រការ៤

ផលប្រយោជន៍ផ្សេងៗទៀតរបស់មន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព និងសំរាលកូននឹងមានកំណត់ដោយឡែក ។

ប្រការ៥

នីតិវិធី និងបែបបទនៃការអនុវត្តសេចក្តីសំរេចនេះ នឹងកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងដោយមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

ប្រការ៦

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះតាមភារកិច្ចរៀង១ខ្លួន។

ប្រការ៧

សេចក្ដីសំរេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ តទៅ៕

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ហត្ថលេខា និងត្រា

**សុខ អាន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- អគ្គស្នងការដ្ឋានឧត្ដមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ

# វិចារណកថា

នាពេលចុងក្រោយនេះ ទស្សនៈនៃ **ការចូលរួម** របស់គ្រប់ផ្នែកពាក់ព័ន្ធក្នុងកម្មវិធី ឬគំរោងអ្វីមួយកាន់តែបញ្ជាក់ និងបង្ហាញពីប្រសិទ្ធភាព និងលទ្ធផលល្អនៃការអនុវត្តកម្មវិធី ឬគំរោងនោះ។

**ការចូលរួម** និងលទ្ធផលរំពឹងទុក បានធ្វើអោយមានការភ្ញាក់ផ្អើល។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង **ការចូលរួម** បានជួបការលំបាក និងបញ្ហាប្រឈមជាច្រើន។ ដូចនេះ វាទាមទារអោយមានការខិតខំជាប្រចាំសំដៅពង្រឹងការយោគយល់គ្នា ទង្វើសមស្របតាមវិចារណញ្ញាណ និងការកែលំអជានិច្ច។

**ការចូលរួម** ជាមធ្យោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីញ៉ាំងអោយភាពជាដៃគូកាន់តែរឹងមាំ កិច្ចសហការកាន់តែស៊ីសង្វាក់គ្នា ឱកាសធ្វើសកម្មភាពរបស់គ្រប់ផ្នែកកាន់តែស្វាហាប់ សមត្ថភាពកាន់តែរីកចំរើន និងរត់ទាន់សភាពការណ៍។ ជោគជ័យនៃ **ការចូលរួម** ស្ថិតនៅលើតម្លាភាពនៃការអនុវត្តទំនាក់ទំនង និងអន្តរកម្មរវាងលទ្ធផលរំពឹងទុក និងសកម្មភាពឆ្ពោះទៅរកគោលដៅ។

ជាក់ស្តែងសំរាប់វិស័យអប់រំ ដំណើរឆ្លងចេញពីសកម្មភាពដោយឯកឯងរបស់សាលារៀនទៅរកការចូលរួមកាន់តែជិតស្និទ្ធរបស់គ្រួសារ និងសហគមន៍ ជារបត់មួយគួរត្រូវបានលើកទឹកចិត្ត និងចាំបាច់ត្រូវតែពុះពារធ្វើអោយបានសំរេច ទោះបីជាមធ្យោបាយនៅមានកំរិត និងមិនទាន់ឆ្លើយតបទាំងស្រុងនឹងបំណងប្រាថ្នារបស់យើងក៏ដោយ។

បន្តិចម្តងៗ វត្ថុបំណងនៃ **ការចូលរួម** របស់យើងនឹងក្លាយជាការពិត។

**គណៈកម្មាធិការនាយក**




## ទំនៀមទំលាប់ប្រពៃណីខ្មែរស្តីពីការអប់រំចរិយាសម្បត្តិ (ត)

### ខ. សំលៀកបំពាក់ទៅបុណ្យខ្មោច_កាន់ទុក្ខ

................................................................................................

**១.កោរសក់កាន់ទុក្ខ**

ការកោរសក់ ស្លៀកស ពាក់សនេះ ជាទំនៀមទំលាប់របស់ជនជាតិខ្មែរជាន់ដើម ជាសញ្ញាសំគាល់ថា អ្នកនោះឯងកាន់ទុក្ខដោយមានសាច់សាលោហិតយ៉ាងជិតទទួលមរណភាព។

- ប្រពន្ធត្រូវកោរសក់ កាន់ទុក្ខប្តី។
- ប្តីមិនត្រូវកោរសក់កាន់ទុក្ខប្រពន្ធទេ (តែនៅសម័យទំនើបនេះ បើសុភាពបុរសខ្លះដែលគេមានទស្សនៈទូលាយ ហើយមានចិត្តស្រឡាញ់ ស្មោះស្ម័គ្រចំពោះភរិយារបស់ខ្លួន គេក៏អាចកោរសក់កាន់ទុក្ខប្រពន្ធរបស់គេដែរ ដែលជាប្រការគំរូមានណាស់។

កូនត្រូវកោរសក់កាន់ទុក្ខមាតាបិតា។ ចៅបង្កើតត្រូវកោរសក់កាន់ទុក្ខជីដូនជីតា។ សិស្សានុសិស្សត្រូវកោរសក់កាន់ទុក្ខលោកគ្រូ-បាអាចារ្យឧបជ្ឈាយ៍។ កូនក្មួយខ្លះដែលគេស្រឡាញ់ម្តាយធំ-ម្តាយមីង ឪពុកធំ-ឪពុកមាក៏គេកោរសក់កាន់ទុក្ខដែរ។

ឯពួកមនុស្សបំរើក្នុងផ្ទះដែលពុំមែនជាញាតិសន្តាន យើងជាម្ចាស់សពដែលមានទ្រព្យសម្បត្តិគ្រាន់បើ ចង់អោយមនុស្សទាំងនោះចូលកាន់ទុក្ខជាមួយផងក្នុងរវាងថ្ងៃធ្វើបុណ្យនោះ គេអាចចែកសំពត់អាវសអោយស្លៀកពាក់ផងក៏មិនទាស់អ្វី ជួនកាលគេអោយកោរសក់ទៀតផង។

**២.រយៈពេលកាន់ទុក្ខ**

កំណត់ពេលកាន់ទុក្ខមិនជាទម្លាប់បង្ខំថា ប៉ុន្មានឆ្នាំ ប៉ុន្មានខែឡើយ ស្រេចហើយតែទ្រាំទ្របាន ព្រោះការកាន់ទុក្ខមិនមែនជាសំលៀកបំពាក់សម្រាប់តាក់តែងខ្លួនប្រាណអោយស្រស់នោះទេ។ យើងដឹងខ្លួនយើងច្បាស់ណាស់ហើយថាយើងមានទុក្ខ ថាយើងមិនសុខ មិនសប្បាយ ថាយើងសោកស្តាយស្រណោះ អាឡោះអាល័យដល់អ្នកដែលព្រាត់

ប្រាស់បាត់បង់ទៅ ដូច្នេះហើយមិនត្រូវថាស្លៀកខ្មៅពាក់ខ្មៅ ឬស្លៀកសពាក់ស ឬប៉ាន់ខ្មៅនៅអាវនោះ អាចនឹងធ្វើអោយខ្លួនយើងល្អស្រស់ជាងធម្មតានោះទេ។

តាមធម្មតា ទម្លាប់ស្រុកអឺរ៉ុបគេចែកពេលកាន់ទុក្ខនេះជាថ្នាក់ៗ គេអោយឈ្មោះថា "ទុក្ខធំ" និង"ទុក្ខពាក់កណ្តាល"។ នោះស្ត្រីមេម៉ាយគេកាន់ទុក្ខអស់រវាង២ឆ្នាំ បុរសពោះម៉ាយគេកាន់ទុក្ខអស់រវាង១ឆ្នាំជាកំណត់។ គេកាន់ទុក្ខ៦ខែសម្រាប់មាតាបិតា ជីដូនជីតា-បងប្អូនប្រុសស្រីបង្កើត-បងថ្លៃ-ប្អូនថ្លៃ, ៣ខែសម្រាប់មា-មីង ឪពុកធំ-ម្តាយធំ, ៦សប្តាហ៍សម្រាប់បងប្អូនជីដូនមួយ-ម្តាយឪពុកចិញ្ចឹម។ បើកូនក្មេង ការកាន់ទុក្ខនេះមិនជាការបង្ខំទេ។

សូមចាំកុំភ្លេចថា ការកាន់ទុក្ខនេះពិបាកបន្តិចហើយ ត្រូវគោរពអោយមែនទែនកុំអោយឆ្គង។ ចំណែកពេលវេលាវិញមិនមែនជាការកំរិតថា ត្រូវតែអោយត្រឹមកំណត់ប៉ុណ្ណេះឆ្នាំ ប៉ុណ្ណេះខែឡើយ យើងតាំងចិត្តបានប៉ុន្មាន ក៏ធ្វើប៉ុណ្ណោះទៅ ក៏ប៉ុន្តែក្នុងរវាងពេលកាន់ទុក្ខនោះ ត្រូវអោយមានការសង្រួមអោយបានបរិបូណ៌។ឯស្ត្រីមេម៉ាយ កាលណាឈប់កាន់ទុក្ខគប្បីស្លៀកពាក់តែសំពត់អាវដែលមានពណ៌មិនឆើតឆាយ ដូចពណ៌ប្រផេះ ពណ៌ដែក-ពណ៌ស្រគាំ។ល។ នេះទើបសមរម្យ លុះត្រាតែមានប្តីទៀត ទើបប្រើប្រាស់តាមរបៀបអ្នកមានប្តី។

មួយទៀត ក្នុងរោងរបាំតួរ្យតន្ត្រី មានល្ខោនជាដើមនោះ មិនមានការហាមប្រាមទេ ក៏ប៉ុន្តែបើយើងនៅក្នុងការកាន់ទុក្ខហើយចូលទៅមើលរបាំអ្នកផងទាំងពួងគេមើលមកហាក់ដូចជាទើសភ្នែកគេ ឬអោយគេកើតទុក្ខអផ្សុកចិត្តដោយសារយើងមិនខាន មិនតែប៉ុណ្ណោះឡើយដូចជាត្រូវគេអញ្ជើញទៅក្នុងមង្គលការអាពាហ៍ពិពាហ៍ ឬទៅទទួលជប់លៀងភោជនាហារពិសារកំសាន្តនោះ ក៏ពុំគួរគប្បីទទួលអញ្ជើញគេអោយសោះ គួរតែតបតាមផ្លូវលិខិត សុំអភ័យទោសគេថា "យើងកំពុងមានកិច្ចជាប់នៅក្នុងតំណមកាន់ទុក្ខ"។ តែបើយើងយល់ថា កិច្ចនេះខានមិនបានត្រូវយើងលាកាន់ទុក្ខជាមុនអោយស្រេចនេះ មិនទាស់ទេ។

ការកាន់ទុក្ខនេះមិនមែនមួយថ្ងៃកាន់ មួយថ្ងៃលានោះទេ បើកាន់ហើយត្រូវកាន់អោយត្រឹមត្រូវតាមពេលកម្រិត បើលាទុក្ខហើយ ត្រូវលាអោយរហូត។

**៣.មិត្តព្រៀងលាន**

យើងជាមិត្ត ឬអ្នកនៅជិតខាងភូមិផងរបងជាមួយ គប្បីសំដែងកាយវាចាចិត្តជួយទទួលរំលែកទុក្ខពាក់កណ្តាលអំពីកូន-ចៅ និងញាតិសាលោហិតនៃសពនោះដែរ។ ពេលហែសពទៅរំលាយ ឬទៅបញ្ចុះ ស្រីៗគប្បីស្លៀកសំពត់ខ្មៅ ខៀនពណ៌ខៀវ-ព្រីងទុំ-ព្រីងទុំក្រមៅ ពាក់អាវសពានាក្រមាស ឬក្រមាដែលមានពណ៌ស្រគាំៗដូចជាហ៊ានសផ្កាខ្មៅ ហ៊ានខ្មៅផ្កាស។

ប្រុសៗគប្បីស្លៀកពាក់សសុទ្ធក៏បាន ពណ៌ស្រគាំៗក៏បាន ចងក្រវាត់ខ្មៅក៏បាន គឺថាកុំប្រើពណ៌ឆើតឆាយ។ ស្បែកជើងពុំមានអោយទាស់ទេ ទោះពណ៌សក្តី-ខ្មៅក្តី-ក្រហមក្តី-លឿងក្តី តែបើអោយសមរម្យតាមរបៀបកាន់ទុក្ខគួរប្រើស្បែកជើង-ស្រោមជើងស និងខ្មៅ។ នេះហៅថាសំដែងការគោរពចំពោះសព និងអ្នកមានទុក្ខ។

យើងបានដំណឹងថា មិត្តព្រៀងលានយើងមានទុក្ខដោយមរណសង្គ្រាម យើងក៏កើតមានចិត្តអាណិតដល់មិត្ត

ព្រៀងលានយើងឬមានចិត្តអាឡោះអាល័យដល់អ្នកស្លាប់ដែលធ្លាប់កំសត់កម្រនឹងគ្នា។ យើងក៏មិនមិនទៅតួរសមនឹងក្រុមញាតិនៅគេហដ្ឋានសព នោះសំលៀកបំពាក់គប្បីស្លៀកពាក់អោយគួរសមដូចមានពោលហើយខាងលើ។

អ្នកទៅបុណ្យខ្មោច ហើយស្លៀកខោបារាំងពាក់តែអាវសឺមិទទេ ឬមានអាវបើកកដែរ តែពុំក្រវាត់ នោះពុំសមរម្យទេ បើប្រសិនជាយើងពាក់អាវកុតកត្រង់នោះប្រសើរជាង សមជាង។

**៨.អ្នកបួសមុខភ្លើង**

អ្នកបួសមុខភ្លើង គប្បីរៀបខ្លួនប្រាណអោយបានស្រួលបួល ព្រោះអ្នកបួសនោះចេញមុខមាត់អោយអ្នកផងឃើញបានរាល់គ្នាក្នុងចំណោមអ្នកកាន់ទុក្ខ។ បើជាស្លៀកសំឡយសំពត់ស ពាក់អាវកុតស ឬអាវចិនស ស្ពាយឈៀងក្រមាជាការសមរម្យណាស់។

ការរៀបរាប់យ៉ាងនេះ ព្រោះបានឃើញច្រើនណាស់មកហើយ អាចារ្យបណ្តោយអោយតែអ្នកបួសមុខភ្លើងខ្លួនទទេ នទល គ្មានពាក់អាវ ធ្វើបែបនេះមិនល្អមើលសោះ។

**គ.សំលៀកបំពាក់ក្នុងឱកាសរៀបមង្គលការ អាពាហ៍ពិពាហ៍**

ការរៀបមង្គលការអាពាហ៍ពិពាហ៍បុត្រធីតាអោយមានស្វាមីភរិយា ជាពិធីមួយរបស់មនុស្សគ្រប់ប្រទេសគ្រប់ជាតិ តែតែងតែធ្វើ ព្រោះជាទំនៀមទម្លាប់សម្រាប់សំគាល់អោយដឹងថា បុត្រធីតាដែលរៀបការជាគូស្រករនេះប្រកបដោយជំបូន្មាននៃមាតា បិតា គ្រូអាចារ្យ ចាស់ទុំ ក្នុងត្រកូលរៀងៗខ្លួន។ តែការរៀបចំផ្សំផ្គុំកូនស្រី និងកូនប្រុសអោយជាប្តីប្រពន្ធមានរបៀបប្លែកៗគ្នាតាមជាតិ តាមប្រទេស។ កុំថាឡើយតែជាតិដទៃ ប្រទេសដទៃ សូម្បីតែជាតិមួយ ប្រទេសមួយផងគ្នា ខុសគ្នាតែខេត្ត និងស្រុកប៉ុណ្ណោះ របៀបរៀបចំមង្គលការក៏រមែងប្លែកអំពីគ្នាខ្លះៗដែរ។

ក្នុងទីនេះ សូមសំដែងតែអំពីសំលៀកបំពាក់ក្នុងឱកាសរៀបមង្គលការអាពាហ៍ពិពាហ៍ៈ

១-សម្រាប់សាមីខ្លួនអ្នកការ។

២-ភ្ញៀវ គឺញាតិសាច់សាលោហិត ជិតឆ្ងាយ ព្រៀងលាន និងមិត្តសំឡាញ់។

បុរាណខ្មែរ សាមីខ្លួនមិនរាប់អានសោះ ពណ៌ស និងពណ៌ខ្មៅ ក្នុងឱកាសរៀបមង្គលការអាពាហ៍ពិពាហ៍។ សូមសង្កេតមើលចុះ សាមីខ្លួនអ្នកការមិនដែលស្លៀកពាក់សំពត់អាវខ្មៅ-សសោះឡើយ គេប្រើតែពណ៌លឿង និងក្រហមជាឯក ពណ៌ឯទៀតៗជាបន្ទាប់បន្សំ។

ដូចជាសាមីខ្លួនកូនប្រុស ពេលស្តាប់ព្រះសង្ឃចំរើនព្រះពុទ្ធមន្ត គេស្លៀកសំពត់សារបាប់ ពាក់អាវសារបាប់។ បើរកសំពត់អាវសារបាប់មិនបាន គេស្លៀកសំពត់ពណ៌ផ្សេងៗ (ផាមួង) ពាក់អាវពណ៌ ឬអាវផ្កាមាស។

ដល់ពេលសំពះទទួលស្ពាន (ផ្ទឹម) គេពាក់អាវផាយពណ៌ក្រហមពីលើអាវសារបាប់ទៅទៀត ឯអស់លោកដែលមានយសសក្តិជាមន្ត្រីធំក្តី តូចក្តី អាវផាយព្រៃក្រហមនោះ មានប៉ាក់ឌិនមាស ជាផ្កាលើសាច់ព្រៃថែមទៀត។ សំពះស្ពាន ហើយផ្លាស់ស្លៀកសំពត់ផាមួងពណ៌ និងអាវកុត ឬអាវចិនពណ៌ទៀតក៏បាន។

ចំណែកសាមីខ្លួនស្រីពេលស្តាប់ព្រះសង្ឃចំរើនព្រះពុទ្ធមន្តក្តី ព្រឹកឡើងផ្ទឹមក្តី សំលៀកបំពាក់គ្រឿងអលង្ការ

ប្រើតែ១បែប ។

គេតែងខ្លួនស្លៀកពាក់តែសំពត់អាវពណ៌ជាងរាប អ្នកមានទ្រព្យសម្បត្តិច្រើនគ្រប់ជាន់គ្រប់ថ្នាក់ គេតែងខ្លួនដូចល្ខោនព្រះរាជទ្រព្យ (គឺដូចស្រីទេពធីតាដែលយើងឃើញក្នុងគំនូរ ខុសគ្នាតែមិនពាក់ម្កុដ) ។ គេស្លៀកសំពត់សារបាប់ ឬសំពត់ល្បើកពាក់អាវទ្រនាប់ពណ៌ក្រហម លឿង ។ល ។ ពាក់ស្បៃប៉ាក់ឱន និងគ្រឿងអលង្ការផ្សេងៗថែមទៀត ។

ចំណែកខាងអ្នកស្រែចំការដែលក្រខ្សត់ប្រដាប់តែងខ្លួនបែបដូចអធិប្បាយខាងលើនេះ គេស្លៀកសំពត់ផាមួង ឬហូល ពាក់អាវបំពង់វែង និងពាទាជាហ៊ុមព្រៃពណ៌ផ្សេងៗ ។

ដល់មកសម័យថ្មីនេះ អ្នកខ្លះផ្លាស់ប្ដូរបែបផែនតែងខ្លួនក្នុងមង្គលការអាពាហ៍ពិពាហ៍នេះ អោយងាយរៀបចំខ្លួនទៅវិញ ដោយហេតុពិបាករកខ្ចី ឬជួលគ្រឿងមកតែងខ្លួនដូចទេពតាពេក ក៏ចាត់ការដេរអាវបែបទំនើបថ្មីតាមសម័យនិយម គឺអាវព្រៃពណ៌ផ្សេងៗ មានតម្លៃក៏គួរសមតាមធនធាន ហើយស្លៀកសំពត់សូត្រពណ៌តាមថ្ងៃ ។

ក្រៅពីបីពេលនេះ ក៏ដោះចេញស្លៀកពាក់តាមបែបតែងខ្លួនអោយស្អាតតាមធម្មតា ។ សោតឯអ្នកផ្លូវចៅមហាទៀតដែលជាអ្នកនិយាយការ និងលោកមេបាចាស់ទុំត្រកូលរៀមច្បងខាងស្រី ក៏មានសំលៀកបំពាក់ពណ៌ជាងរាប អ្នកមហាមានអាវផាយក្រហម ពាក់ជាយសសក្តិសម្រាប់មុខងារ ។ ការដែលយើងរៀបរាប់បន្តិចនេះ គ្រាន់តែបញ្ជាក់អោយឃើញថា ខ្មែរពីបុរាណរាប់អានសំពត់អាវពណ៌ក្នុងឱកាសរៀបមង្គលការអាពាហ៍ពិពាហ៍ ។

(នៅមានត)

លោកស្រី ឈឹម ចន្ទតារា
អធិការបឋមសិក្សា

### ពាក្យប្រស្នា

ឈ្មោះសត្វចតុប្បាទព្រៃមួយ កាលបើគេកាត់ក្បាលចេញ គេអាចយកខ្លួនវាទៅច្នៃជាគ្រឿងអលង្ការបាន ។

១_តើចតុប្បាទនោះឈ្មោះអ្វី?

២_តើវត្ថុធាតុដែលយកមកច្នៃជាគ្រឿងអលង្ការជាអ្វី?

(ចំលើយនៅទំព័រទី ៣០)

ថែម យ៉ារ

ដកស្រង់ចេញពី : សៀវភៅ "ទំនៀមទំលាប់ និងប្រពៃណីខ្មែរ" (អប់រំចរិយាសម្បត្តិ) របស់ឧកញ៉ាមហាមន្ត្រី ញ៉ុក ធន ឆ្នាំ១៩៥៩



# សិល្បៈនៃការនិយាយក្នុងថ្នាក់រៀន

សិល្បៈនៃការនិយាយស្តែងចេញដោយការពោលពាក្យពេចន៍ដែលនឹងធ្វើអោយអ្នកស្តាប់យល់ ជក់ចិត្ត និងមានការសប្បាយរីករាយ ព្រមទាំងបានទាក់ទាញចិត្តអ្នកស្តាប់អោយមានជំនឿទុកចិត្តលើអ្នកនិយាយផងដែរ។ ការនិយាយដែលធ្វើអោយអ្នកស្តាប់ពេញចិត្ត យល់បាននោះ គឺអាស្រ័យទៅនឹងទឹកសំលេង ឬសំនួនវោហារដែលជ្រួតជ្រាបក្នុងដួងចិត្តអ្នកស្តាប់ ហើយបានធ្វើអោយគេរីករាយ និងមានខ្លឹមសារដែលអាចទទួលបាន និងអនុវត្តបាន។

ក្នុងថ្នាក់រៀនមួយដែលសកម្ម គឺជាថ្នាក់ពោរពេញទៅដោយភាពស្រស់ស្រាយដែលបង្កើតដោយគ្រូដែលប៉ិនប្រសប់ក្នុងការនិយាយ។ តែទោះយ៉ាងនេះក្តី នៅតែមានថ្នាក់ខ្លះស្ងាត់ជ្រៀបដែលបង្កភាពធុញទ្រាន់ដល់សិស្សជាអ្នកស្តាប់ ហើយក៏តាំងមានសិស្សខ្លះស្ងាប សិស្សងាកមកជជែកគ្នា សិស្សខ្លះគ្មានអារម្មណ៍នៅក្នុងខ្លួនរហូតដល់មានសិស្សខ្លះដេកទៀតផង។ កាយវិការទាំងនេះសបញ្ជាក់ថា គ្រូពុំមានទឹកដមសំដីធ្វើអោយសិស្សជក់ចិត្តជិតអារម្មណ៍ឡើយ។ ដើម្បីទទួលបាននូវការយកចិត្តទុកដាក់នឹងការចាប់អារម្មណ៍ និងការស្វែងយល់ពីសិស្ស គ្រូគប្បីត្រូវមានសិល្បៈនៃការនិយាយ ដើម្បីធ្វើអោយថ្នាក់រៀននោះរស់រវើកឡើង។ ពិតមែនហើយ អ្នកខ្លះយល់ថា ការនិយាយគឺជាប៉ិនិតពីកំណើត។ អ្នកខ្លះពូកែនិយាយទាក់ទាញ តែអ្នកខ្លះទៀតពុំមានវោហារគ្រប់គ្រាន់សំរាប់ទាក់ទាញឡើយ។ ការយល់ដូច្នេះ ក៏ត្រឹមត្រូវម្យ៉ាងដែរ តែនាសម័យឥឡូវនេះ គេអាចកែប្រែទំលាប់មិនប្រសប់និយាយបានដោយសិក្សាស្រាវជ្រាវនូវគំនិតមួយចំនួន។ ចំពោះលោកគ្រូ អ្នកគ្រូខ្លះពូកែធ្វើអោយថ្នាក់រៀនស្រស់បំព្រងដោយប្រើនូវកាយវិការ ពាក្យសំដីដ៏គួរអោយទាក់ទាញ។

តើអ្វីទៅជាសិល្បៈនៃការនិយាយ?

មាននិយមន័យជាច្រើនស្តីពី "ការនិយាយ" តែពេលនេះសូមលើកតែទស្សនៈមួយចំនួនដែលទាក់ទងនឹងការនិយាយក្នុងថ្នាក់រៀន។

ការនិយាយ គឺជាសកម្មភាពរួមគ្នានឹងការស្តាប់ដែលជាប្រតិកម្មតបត ហើយដើម្បីអោយបានផលល្អជាទីពេញ

ចិត្តនោះ គួរមានគោលការណ៍ និងសិល្បៈសមស្របផង។ ការនិយាយល្អ គឺជាការនិយាយអោយអ្នកដទៃដឹងអំពីគោលបំណងរបស់អ្នកនិយាយនោះ មិនមែនជារឿងដែលធ្វើបានដោយងាយៗនោះទេ។

យើងអាចចែកគោលបំណងនៃការនិយាយជាប្រាំពីរចំណុច គឺនិយាយដើម្បី ÷

១-បង្កើនចំណេះដឹង

២-ធ្វើអោយមានការយោគយល់រវាងគ្នានិងគ្នា

៣-បញ្ចេញទុក្ខកង្វល់ក្នុងចិត្ត ធ្វើអោយអារម្មណ៍ធូរស្រាល

៤-ធ្វើអោយមានភាពសប្បាយរីករាយ

៥-បើកឱកាសអោយអ្នកស្តាប់សួរដេញដោលពីបញ្ហាសង្ស័យ និងបង្កើនភាពច្បាស់លាស់បំបាត់ភាពស្មុគស្មាញផ្សេងៗដែលកំពុងប្រឈមមុខ

៦-លួងលោម និងទាក់ទាញចិត្ត

៧-ធ្វើអោយអ្នកស្តាប់មានទំនុកចិត្ត ជឿជាក់ ហើយផ្លាស់ប្តូរទស្សនៈរបស់ខ្លួន។

នៅក្នុងថ្នាក់រៀន គ្រូត្រូវចាំបាច់ត្រៀមខ្លួន និងមានលក្ខណៈសម្បត្តិមួយចំនួនដូចជា :

- **អត្តចរិត** : ត្រូវស្លៀកពាក់អោយសមរម្យទៅតាមឋានៈជាគ្រូបង្រៀន កាយវិការ ទឹកមុខ ឬការធ្វើចលនាគួរអោយទៅតាមធម្មជាតិ។ ត្រូវសំលឹងមើលមុខសិស្សជានិច្ច តែមិនត្រូវញញាក់មុខមាត់ឡើយ។
- **ការប្រើសំលេង** : សំលេងមានសារៈសំខាន់ណាស់ក្នុងការនិយាយ។ គួរនិយាយអោយច្បាស់មិនទាក់រអាក់រអួល ដើម្បីបង្ហាញនូវភាពជឿជាក់ ហើយត្រូវនិយាយអោយសិស្សស្តាប់លឺគ្រប់ៗគ្នា ប៉ុន្តែមិនគួរខ្លាំង ឬតិចពេកទេ ហើយក៏មិនអោយយឺត ឬលឿនពេកដែរ។ គួរព្យាយាមធ្វើអោយដូចសំលេងនិយាយកុំអោយដូចសំលេងអាន សូត្រ ឬទេសនា។ ត្រូវចេះលើកដាក់សំលេងឈប់សំរាកដកដង្ហើម និងនិយាយសួនប្រយោគណាសំខាន់ ប៉ុន្តែមិនត្រូវនិយាយច្រំដែលពេកទេ។
- **ភាសាដែលប្រើ** : គួរប្រើពាក្យពេចន៍ដែលសាមញ្ញងាយស្រួលយល់។ ប្រើពាក្យសំដីពន្យល់ត្រូវមានសិល្បៈឆ្លៀតឱកាសទាញយកចំណេះដឹងទូទៅ រឿងកំប្លែងដែលទាក់ទងប្រធានបទដែលកំពុងតែបង្រៀន ដើម្បីផ្លាស់ប្តូរបរិយាកាស។

ចរិយាក្នុងការនិយាយ ត្រូវមានចិត្តសាស្ត្រ ហើយគួរពឹងគិតដល់ទំនោរចិត្ត និងតំរូវការរបស់សិស្ស ត្រូវចេះប្តូររឿងនិយាយ បើកាលណាឃើញថា សិស្សមិនយកចិត្តទុកដាក់ស្តាប់។ កុំប្រមូលការនិយាយធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនម្នាក់ឯងផ្តាច់មុខ ដោយមិនទុកអោយសិស្សសួរអោយសោះ។ កុំទាន់និយាយកាត់ ឬបន្ថែម បើមិនទាន់មានឱកាស។

ពេលដែលនិយាយ ចូរកុំភ្លេចមើលសិស្សដែលកំពុងស្តាប់ផង ព្រោះសិស្សមានច្រើនប្រភេទ និងកិរិតខុសៗគ្នា:

**១.សិស្សអៀនខ្មាស់** : សិស្សប្រភេទនេះ ច្រើនតែស្ងៀម ឬក្រឡេកមើលអ្នកនេះ ក្រឡេកមើលអ្នកនោះ

នៅពេលដែលគេនិយាយ ។ ពេលដែលត្រូវចោទសួរម្តងៗ គេក៏អៀន ហើយងាកឆ្វេងស្តាំមិនព្រមនិយាយ ។

វិធីដោះស្រាយ : ត្រូវសួរគេជាញឹកញាប់ និងព្យាយាមធ្វើអោយគេមានជំនឿជាក់លើខ្លួនឯង ។ ពេលគេឆ្លើយត្រូវសរសើរ ហើយប្រើគំនិតគេជាគំរូញយៗផង ដើម្បីអោយគេមានទឹកចិត្ត ។

***២-សិស្សមិនយកចិត្តទុកដាក់*** : សិស្សប្រភេទនេះ ច្រើនតែមិនព្រមនិយាយអ្វីឡើយ ជួនកាលអាចដេកលក់ក៏មាន ។

វិធីដោះស្រាយ : គួរសួរដេញដោលពីបញ្ហាផ្ទាល់ខ្លួនរបស់គេ បង្កើនការរាក់ទាក់ ដើម្បីអោយគេចាប់អារម្មណ៍ ត្រូវស្គាល់ឈ្មោះ និងហៅចំឈ្មោះរបស់គេ ហើយសួរសំណួរស្រាលៗ ទោះបីចំ ឬមិនចំប្រធានបទបង្រៀនក៏ដោយ ។

***៣-សិស្សចេះតែខុស*** : សិស្សប្រភេទនេះ ច្រើនតែប្រកែកមិនឈប់ ហើយគិតថាខ្លួនត្រូវដោយសំអាងលើសំដីគ្រូមុន ឬឯកសារផ្សេងៗ ។

វិធីដោះស្រាយ : ត្រូវលើកសំណួរចំលើយរបស់គេអោយសិស្សដទៃវិភាគ និងបញ្ចេញយោបល់ ។ ប្រសិនបើមិនសំរេចទេ អោយគេរង់ចាំនិយាយនៅពេលក្រោយ ដើម្បីចៀសវាងសិស្សដទៃធុញទ្រាន់ ។

***៤-សិស្សដែលគ្មានចំណេះដឹង*** : សិស្សគ្មានការយល់ដឹង គឺមិនយល់ពីអ្វីដែលគ្រូកំពុងនិយាយឡើយ តែយកចិត្តទុកដាក់ស្តាប់ ។

វិធីដោះស្រាយ : ត្រូវស្រង់យកចំណុចសំខាន់នៃមេរៀនសង្ខេបបែបងាយជូនពួកគេ និងអោយស្វែងរកគំនិតអ្វីក៏ដោយ តាមការយល់ឃើញរបស់ពួកគេ ដើម្បីស្រាយបំភ្លឺ ។

នៅពេលបញ្ចប់ ការនិយាយត្រូវសួរសំណួរខ្លីៗ ដើម្បីរំលឹកការនិយាយ ការពន្យល់របស់ខ្លួន ហើយត្រូវប្រើវិធីសួរប្រកបដោយថាមពលដូចជា:

- សួរដើម្បីអោយឆ្លើយខ្លីៗថា ពិត ឬមិនពិត ( សំរាប់សិស្សខ្សោយ)
- សួរដើម្បីអោយបានចំលើយដូចដែលស្មានទុក ( សំរាប់សិស្សមធ្យម)
- សួរដើម្បីអោយអធិប្បាយពន្យល់ ( សំរាប់សិស្សពូកែ)
- សួរដើម្បីបញ្ចេញយោបល់ ( សិស្សទូទៅ) ។

ធ្វើបែបនេះ ដើម្បីអោយពួកគេឆ្លើយត្រូវគ្រប់គ្នា ទាំងសិស្សខ្សោយ មធ្យម ពូកែ ក្នុងគោលបំណងលើកទឹកចិត្ត និងផ្តល់ចំណេះដឹង អ្នកពូកែជួយអ្នកខ្សោយ និងមធ្យម ធ្វើអោយពួកគេទទួលនូវគុណតំលៃស្មើៗគ្នា៕

លោក អួន ស៊ីវឌ្ឍន
សាស្ត្រាចារ្យភាសាអង់គ្លេស
វិ.ហ៊ុន សែនបល្ល័ង្កកំពង់ធំ




## តើយើងអាចបំបាត់ជំងឺស៊ីដា SIDA(*) នាពេលអនាគតដ៏ខាងមុខបានទេ?

តាំងពីជំងឺស៊ីដា (SIDA) កកើតរីកសាយភាយក្នុងឆ្នាំ១៩៨១មក ជំងឺនេះបានព្យាបាទជីវិតមនុស្សប្រុស ស្រី និងក្មេងៗរាប់សិបលាននាក់ហើយ ។ វាជាជំងឺឆ្លងដ៏សាហាវដែលរាតត្បាតពេញទាំងពិភពលោកយើងនេះ ។ ក្រោយពីការស្រាវជ្រាវអស់រយៈពេលជាង១០ឆ្នាំមក តើយើងមានសេចក្ដីសង្ឃឹមយ៉ាងណាទៅចំពោះការបំបាត់ជំងឺដ៏អាក្រក់នេះបាន? សាស្ត្រាចារ្យ ម៉ាក្ស-ហ្ស៊ីរ៉ា (Marc-Girard) ជានាយករងនៃវិទ្យាស្ថានប៉ាស្ទ័រ លោកបានឆ្លើយសំណួររបស់យើងដូចខាងក្រោម ÷

- **តើអ្វីទៅជាជំងឺ SIDA ?**

+ លោកសាស្ត្រាចារ្យ ហ្ស៊ីរ៉ា : "ស៊ីដា អាចនិយាយថា Syndrome d'immuno-déficience acquise" គឺជាជំងឺមួយកើតឡើងដោយសារវីរុស គឺវីរុស VIH (Virus de l'immuno-déficience humaine) ។

ការព្យាបាទ ការរាលដាលនៃវីរុស VIH លើជីវិតមនុស្ស ដោយសារវីរុសនេះមាននិទីបំផ្លាញកោសិកាការពារសារពាង្គកាយរហូតដល់ទៅអស់រលីងនូវប្រភពកំលាំងការពារក្នុងខ្លួន ។

មនុស្សមានជំងឺស៊ីដា គឺវាបង្កចេញពីឥទ្ធិពលដទៃផ្សេងទៀតដូចជា: ជំងឺរលាកទងសួត ជំងឺរបេង ជំងឺមហារីក... គេហៅជំងឺនេះថា ជា"ជំងឺឱកាសនិយម" ពីព្រោះវាឆ្លៀតឱកាស កឡើងនៅពេលសុខភាពយើងចុះខ្សោយ ។

- **តើអ្នកជំងឺអាចជាបានទេ បើគេបានដឹងជាមុនថាជាប់មេរោគស៊ីដាជាលើកដំបូង?**

+ លោកសាស្ត្រាចារ្យ ហ្ស៊ីរ៉ា : ចាប់ពីឱកាសដែលនរណាម្នាក់កើតមានវីរុសស៊ីដា សារពាង្គកាយរបស់គាត់បានបង្កើតប្រព័ន្ធកំលាំងការពារ ដើម្បីប្រយុទ្ធនឹងវីរុស ។

តេស្តពិនិត្យឈាមអ្នកផ្ទុកវីរុស VIH បានបញ្ជាក់ច្បាស់ថា មានវត្តមានសារធាតុការពារសារពាង្គកាយនៅក្នុងឈាមក្រហម ជាពិសេសទៅទៀត នៅក្នុង (Sérum) ឈាមស ។

តេស្តនោះបានប្រាប់ទៀតថា មនុស្សបានផ្ទុកនូវមេរោគ SIDA "Séropositive" ហើយ ។ តែគាត់ពុំទាន់ជា

(*) សរសេរអក្សរកាត់ពីភាសាបារាំង-ចំណែកភាសាអង់គ្លេស : AIDS, ភាសាខ្មែរ អេដស៍

អ្នកជំងឺទេ ក៏ប៉ុន្តែគាត់នឹងអាចឈឺនៅថ្ងៃណាមួយ ពីព្រោះមានវីរុសនៅក្នុងខ្លួនរបស់គាត់ ហើយគាត់ក្លាយជាភ្នាក់ងារចំលងទៀតផង"។

- **តើជំងឺ SIDA ឆ្លងរបៀបណាទៅ?**

+ លោកសាស្ត្រាចារ្យ ហ្សីរ៉ា : វីរុសមាននៅពេញទាំងក្នុងខ្លួនមនុស្សឈឺ វាមាននៅក្នុងឈាម ទឹកកាម ទឹកដោះម្តាយ។

វីរុសស៊ីដា មិនវសាត់តាមខ្យល់ដូចវីរុសជំងឺផ្តាសាយទេ។ វាឆ្លងតាមរយៈការរួមភេទ។

វាឆ្លងតាមឈាម ឧទាហរណ៍ប្រសិនបើមានតំណក់ឈាមតូចមួយជាប់នៅក្នុងសឺរាំងចាក់ថ្នាំដែលពពួកអ្នកញៀនថ្នាំប្រើប្រាស់សំរាប់ចាក់ថ្នាំញៀនចូលទៅក្នុងឈាមតាមសរសៃ តំណក់ឈាមអាក្រក់នេះវានឹងរីកដុះដាលឡើង។

វីរុសស៊ីដា ឆ្លងពីម្តាយទៅកូននៅពេលគាត់ឆ្លងទន្លេ ឬពេលដែលគាត់បំបៅកូននោះផងដែរ។

- **តើអ្នកផ្ទុកមេរោគស៊ីដា នឹងក្លាយជាអ្នកមានជំងឺ SIDA ទាំងអស់ ឬយ៉ាងណាដែរ?**

+ លោកសាស្ត្រាចារ្យ ហ្សីរ៉ា : មនុស្សទាំងឡាយណាដែលផ្ទុកទៅដោយវីរុសស៊ីដា ឈានទៅរកទីបញ្ចប់ គឺមានជំងឺស៊ីដាតែម្តង។ អ្នកជំងឺបានឈឺកុំរៃក្នុងរយៈពេលពី៦ខែ ទៅដល់១០ឆ្នាំដែរ។

សព្វថ្ងៃក្នុងចំណោមមនុស្សផ្ទុកមេរោគស៊ីដា អ្នកខ្លះមានអាយុកាលបាន១០ឆ្នាំ ទើបស្លាប់។ រីឯអ្នកខ្លះទៀតបានអាយុវែង ឬខ្លី អាស្រ័យលើជំងឺធ្ងន់ ឬស្រាល។

អ្នកស្រាវជ្រាវអោយតម្លៃខ្ពស់ថា មានភាគរយតូចណាស់ចំពោះអ្នកផ្ទុកមេរោគស៊ីដាហើយ តែពុំទាន់បានឈឺ តើវាមានលក្ខណៈពិសេសសំរាប់ពួកគាត់មានអាយុវែងផងទេ?

- **ក្នុងដំណើរឈានឡើងនៃជំងឺនេះ តើមានខុសប្លែកគ្នាយ៉ាងណាខ្លះ ពីប្រទេសមួយទៅប្រទេសមួយទៀត?**

+ លោកសាស្ត្រាចារ្យ ហ្សីរ៉ា : នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការរីកចំរើននៃជំងឺស៊ីដា មានល្បឿនខ្លាំងក្លាណាស់ អ្នកជំងឺស្លាប់ក្នុងរយៈពេលពីរ ឬបីខែ មូលហេតុមកពីពួកគាត់ខ្វះជីវភាពម្យ៉ាង ម្យ៉ាងទៀតខ្វះអនាម័យ និងការថែទាំសុខភាព។

ជាអាទិ៍ នៅទ្វីបអាហ្វ្រិក អ្នកជំងឺស៊ីដាភាគច្រើនកកើតឡើងដោយអតិសុខុមប្រាណនៃប៉ារ៉ាស៊ីត (Parasites) ដូចជាជំងឺគ្រុនចាញ់ ឬប្រភេទវីរុសដទៃទៀត ហើយក៏វាបណ្តាលមកពីកង្វះថ្នាំសង្កូវសំរាប់ព្យាបាលផងដែរ!។

- **សព្វថ្ងៃតើការស្រាវជ្រាវអំពីជំងឺស៊ីដា (SIDA) នៅត្រឹមកន្លែងណាទៅ?**

+ លោកសាស្ត្រាចារ្យ ហ្សីរ៉ា : យើងស្គាល់ជំងឺនេះច្បាស់លាស់ណាស់ តែយើងមិនអាចរកឃើញថ្នាំការពារមកប្រឆាំងនូវវីរុសនេះបាន។

ការស្រាវជ្រាវជាភារកិច្ចរបស់វិទ្យាស្ថានប៉ាស្ទ័រ ក្នុងនោះយើងរកឃើញថ្នាំការពារមួយមុខដែរ វាអាចជួយជីវិតស្វាឌី (Chimpanzé) មួយប្រឆាំងបាននូវវីរុសម្យ៉ាងដែលអាចក្លែងទ្រង់ទ្រាយរបស់វាបានតែពីរ រឺបីយ៉ាងប៉ុណ្ណោះ។

នេះជាការរីកចំរើនមួយហើយ ក៏ប៉ុន្តែយើងត្រូវឈានទៅរកថ្នាំការពារណាដែលអាចប្រឆាំងបានចំពោះវីរុស

ដែលប្លែងរូបរាងរបស់វាដល់ទៅជិត៣០០ទ្រង់ទ្រាយឯណោះ! ដូច្នោះ យើងរកពុំទាន់ឃើញថ្នាំការពារនេះបានឆាប់ៗទេ។

- **ហេតុអ្វីបានជាយើងលំបាករកថ្នាំការពារសក្តិសិទ្ធិម្ល៉េះ?**

+ លោកសាស្ត្រាចារ្យ ហ្ស៊ីរ៉ា : វាជាបញ្ហាធំណាស់ គឺជាវីរុសមួយប្រភេទដែលអាចប្តូរទ្រង់ទ្រាយ ពីសភាពដើមរបស់វាបានជាអចិន្ត្រៃយ៍។

នរជនណាម្នាក់ឈឺហើយ សរីរាង្គនៃរាងកាយបង្កើតកងកំលាំងប្រព័ន្ធការពារសារពាង្គកាយ-ជីវិត ដើម្បីប្រយុទ្ធប្រឆាំងនឹងសត្រូវ (VIRUS VIH)។ កំលាំងប្រព័ន្ធការពារ ប្រឈមមុខបានត្រឹមតែវីរុសពីរ បីប្រភេទដែលវាបានស្គាល់ច្បាស់។

ពេលដែលសារពាង្គកាយយើងបង្កើតបានកងកំលាំងថ្មីទៀតស្របនឹងទំរង់ ទ្រង់ទ្រាយថ្មីរបស់វីរុសហើយ វីរុសនោះក៏បំប្លែងខ្លួនបានជារូបរាងផ្សេងទៀតទៅ។ នេះគឺជាការរត់ដេញតាមគ្មានគោលដៅរបស់កងកំលាំងប្រភពការពារនៃសារពាង្គកាយ-ជីវិតយើង។ ជាការពិតណាស់ វីរុសអាក្រក់នេះ វាប្តូរទ្រង់ទ្រាយច្រើនទៅទៀត ប្រសិនបើវាបានចំលងខ្លួនវាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត...។

- **ការបង្កើតថ្នាំការពារមានការលំបាក តើគេអាចរកឃើញថ្នាំព្យាបាលទេ?**

+ លោកសាស្ត្រាចារ្យ ហ្ស៊ីរ៉ា : ថ្នាំព្យាបាលមានពីរបីមុខដែរ គឺជាលទ្ធផលរបស់ AZT DDI DDC ជាដើម សុទ្ធតែជាថ្នាំការពារវីរុសប្រយុទ្ធប្រឆាំងវីរុស ដោយធ្វើអោយវីរុសចុះខ្សោយឥទ្ធិពល ហើយរលាយសាបសូន្យ មិនអាចឈានទៅបង្កបង្កើតកូនចៅបានទៀតផង។

ជាអកុសល ផលិតផល (ថ្នាំព្យាបាល) នេះរាថយចំពោះជំងឺឱកាសនិយម ហើយក៏វាមិនអាចជួយជីវិតអ្នកជំងឺបានទៀតផង។

- **តើបានលទ្ធផលដូចម្តេចទៅ ចំពោះការស្រាវជ្រាវ?**

+ លោកសាស្ត្រាចារ្យ ហ្ស៊ីរ៉ា : "នៅក្នុងសាលពិសោធន៍ យើងបានលទ្ធផលត្រឹមតែគួរអោយល្អមើល និងចាប់អារម្មណ៍ប៉ុណ្ណោះ។ យើងនឹងរៀបចំការងារមួយដែលមានកោសិកាបំភាន់វីរុសបញ្ឆោតវីរុសនោះ"។

ជាគំនិត គឺជាការចិញ្ចឹម និងផ្សាំកោសិកាអោយខ្លាំងពូកែ ហើយយកវាមកបណ្តុះនៅលើខ្លួនអ្នកជំងឺត្រង់កន្លែងណាមួយ។ បទពិសោធន៍នេះត្រូវបានគេអនុវត្តទៅលើអ្នកជំងឺហើយ..."!

តែ ចំពោះខ្ញុំមិនសូវពេញចិត្តទេ ពីព្រោះវិទ្យាសាស្ត្រនេះគ្មានព្រំដែនច្បាស់លាស់ ម្យ៉ាងទៀតចំណេះដឹងរបស់ខ្ញុំនៅមានកំរិត៕

**ដោយលោក ឱ សាវ៉ាន់**

**មន្ត្រីអប់រំចូលនិវត្តន៍**

**បកប្រែពី** Propos recueillis par

Sylvaine de Paulin **ក្នុង** OKAPI-94




# ការអប់រំ

## I. និយមន័យនៃការអប់រំ

១-ការអប់រំ មានន័យថា "អប់បង្ហប់ផ្សែង ឬបង្ហប់ចំហាយ ។ បង្ហាត់ចិត្ត, បង្វឹកចិត្ត, ជួសជុលចំពោះវិជ្ជា ឬកិរិយាមារយាទ, ហ្វឹកហាត់អោយស្ទាត់ជំនាញជាងមុន, កែអោយបានល្អជាងមុនជាលំដាប់ ខំប្រឹងបំពេញឧបនិស្ស័យអោយបរិបូណ៌, ខំកសាងសន្សំបុណ្យកុសលរក្សាទុកពុំអោយមានហ្មង, មិនអោយមានថ្នាំងថ្នាក់, បន្ទុំបារមី...."[១] ។

២-ការអប់រំ ជាការបណ្ដុះបណ្ដាល និងណែនាំជាពិសេសសំរាប់កុមារ និងមនុស្សក្មេងៗនៅក្នុងសាលារៀន ឬមហាវិទ្យាល័យ ។ល។ ដោយផ្ដល់ចំណេះដឹង និងការអភិវឌ្ឍបំណិន ឬការអភិវឌ្ឍចរិតលក្ខណៈអំពីស្មារតី សីលធម៌ និងរូបរាងកាយដែលបានមកពីការអប់រំ[២] ។

៣-ការអប់រំ ជាចំណេះដឹងដែលត្រូវមានទំនាក់ទំនងក្នុងបរិបទជាច្រើនយ៉ាងសំខាន់ ជាមួយវិធីសាស្ត្រនៃការបង្រៀន និងការសិក្សាក្នុងសាលារៀន ឬបរិស្ថាននានាដែលនៅចំពោះមុខ ហើយមានពត៌មានផ្សេងៗគ្នានៃបញ្ហាសង្គម ជាពិសេសទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន[៣] ។

៤-ការអប់រំ ជាទង្វើនៃការបណ្ដុះបណ្ដាល និងការបង្រៀនទនរណាម្នាក់ ដោយធ្វើយ៉ាងណាអោយគេយល់ ហើយគេនឹងចេះបែងចែកចំណេះដឹង ដោយបញ្ចេញស្នាដៃក្នុងការបណ្ដុះបណ្ដាល[៤] ។

៥-ការអប់រំ ជាទង្វើលើមនុស្សលោក ដើម្បីនាំពួកគេឆ្ពោះទៅរកគោលដៅមួយដែលបានកំណត់រួចហើយ គឺមានន័យថាផ្ដល់នូវសោភណភាព ហើយនិងការបំពាក់បំប៉នដំណួតខ្មោះដែលគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើកិច្ចការផ្សេងៗ ហើយចំណេះដឹងទាំងនោះសណ្ឋិតជាប់ក្នុងព្រលឹង ខ្លួនប្រាណ ពោលគឺជាការបណ្ដុះស្មារតីទឹកចិត្តដល់បុគ្គលម្នាក់ៗ។ គេអាចបែងចែកការអប់រំជា ការអប់រំកាយ អប់រំបញ្ញា អប់រំសីលធម៌ និងអប់រំពលរដ្ឋវិជ្ជា[៥] ។

---

(១)សូមមើលសម្ដេចសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ ភ្នំពេញ.១៩៣៨ ទំ ព័រ ១៦៤៥

(២) Cf. Oxford Advancer Learner's Dictionary, London, 1992,p-284

(៣) Cf. Word Book, Micropadia Ready, New York, 1997, p-373

(៤) Cf. Le Petit Larousse, Paris, 1993, p-370

(៥) Cf. Ministère de l'Education Nationale Cours de Perfectionnement Pédagogique UNICEF, 1966, p-4

៦-លោកចន ដឺវី (John Dewey) ជាទស្សនវិទូអាល្លឺម៉ង់ បានអោយនិយមន័យថា ការអប់រំជាលំនាំនៃអំពើដែលប្រព្រឹត្តទៅលើបុគ្គលពេញមួយជីវិត និងមានគោលដៅជាក់លាក់ ក្នុងបំរែបំរួលចិត្តគំនិត បុគ្គលិកលក្ខណៈមនុស្សទៅតាមស្ថានភាពផ្សេងគ្នា[៦] ។

៧-លោក ប្លាតុង (Platon) ៤២៧-៣៤៧មុនគ.ស បានពន្យល់ថា ការអប់រំគឺជាការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្សម្នាក់ៗ ដើម្បីលើកកំពស់សុភមង្គលបុគ្គលម្នាក់ៗ និងអភិវឌ្ឍរដ្ឋាភិបាល ។

៨-លោក គន់ ជុង ជាគរុវិទូចិន បានពោលថា ការអប់រំជាមាគ៌ាដែលមិនអាចខ្វះបានចំពោះភាពខ្លាំងរបស់កងកម្លាំង ក៏ដូចជាភាពរុងរឿងរបស់ប្រទេសជាតិ ។ ការអប់រំជួយដល់ប្រជាពលរដ្ឋអោយចេះប្រើសិទ្ធិភារៈឧបទេស ដោយឈរលើមូលដ្ឋានបច្ចេកវិទ្យា និងវិធានការផ្សេងៗ ។

៩-លោក ខុង ជឺ (ចិន) បានអះអាងថា ការអប់រំគឺជានយោបាយ និងជាទស្សនិយមដោយសង្កត់ធ្ងន់ថា ការអប់រំទ្រព្យសម្បត្តិ និងមនុស្សជាកត្តាសំខាន់ក្នុងការស្ថាបនាប្រទេសជាតិ ។

១០-លោក ភូ ជឺ (៣១៣-២៣៨មុនគ.ស) បានពោលថា ការអប់រំ គឺជាការលំអមនុស្សដំបូងគេបង្អស់ ។

ដូច្នេះ ការអប់រំគឺជាការបណ្ដុះបណ្ដាល ឬការណែនាំដល់បុគ្គលគ្រប់រូបទាំងក្នុងសាលារៀន និងក្រៅសាលារៀន ដើម្បីអោយបុគ្គលនោះមានការប្រែប្រួលទាំងចំណេះដឹង បំណិន សីលធម៌ រូបរាងកាយ ដើម្បីឆ្ពោះទៅរកការរីកចំរើន ហើយក្លាយទៅជាមនុស្សថ្លៃថ្នូរក្នុងសង្គម ។

## II. គោលការណ៍អប់រំ

គោលការណ៍នៃការអប់រំរួមមានចំនួន ៧ គឺ:

១- សុខភាព

២- ការរៀបចំខ្លួន

៣- ការគោរពស្រឡាញ់មនុស្សដូចមនុស្សក្នុងគ្រួសារតែមួយ

៤- ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ

៥- ការអប់រំពលរដ្ឋវិជ្ជា

៦- ការប្រើប្រាស់តម្លៃនៃពេលវេលាកំសាន្ត

៧- ការបណ្ដុះតម្លៃសីលធម៌ ។

គោលការណ៍អប់រំទាំង ៧ ជាគោលការណ៍ដែលអ្នកអប់រំទាំងឡាយគួរយកចិត្តទុកដាក់ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សក្នុងអតីតកាល បច្ចុប្បន្នកាល ក៏ដូចអនាគតកាលដែរ ។ លោក Petter Oliver ជនជាតិអាមេរិក បានពោលថា "អ្នកអប់រំ បើមិនបានចូលរួមចំណែកជំរុញគោលការណ៍អប់រំខាងលើនោះទេ អ្នកនោះឯងមិនមែនជាអ្នកអប់រំឡើយ"[៧] ។

## III. គោលដៅនៃការអប់រំ

តើគោលដៅនៃការអប់រំមានបំណងទៅរកអ្វីខ្លះ?

សំណួរបែបនេះមានចំលើយជាច្រើនចាប់តាំងពីអតីតកាលរហូតដល់បច្ចុប្បន្នកាលនេះ ។ ដើម្បីរកចំលើយនេះ ឃើញលុះត្រាតែយើងធ្វើការពិភាក្សាគ្នាអោយបានផុសផុល ព្រោះមនុស្សក្នុងសង្គមមានទស្សនៈផ្សេងៗគ្នាទៅតាមការពិចារណារបស់គេម្នាក់ៗទៅលើអ្វីដែលពួកគេបានសិក្សានៅសាលារៀន និងក្រៅសាលារៀន ។

(៦) Cf. Suzanne Lowell Krogh, Educating Young Children, New York, 1994, p-23

(៧) Cf. Allan c.Ornstein Strategies for Effective Teaching, University of Chicago, 1995, p-86

ជាទូទៅមនុស្សអាចប្រមើលមើលគោលដៅនៃការអប់រំតាមរយៈកម្មវិធីសិក្សា ដែលគេបានរៀបចំដាក់អោយអនុវត្តនៅក្នុងសាលារៀន។ តើគេយកអ្វីមកបង្រៀន ហើយគេបង្រៀនវាដូចម្ដេចខ្លះ?

បើយោងទៅលើខ្លឹមសារនៃកម្មវិធីសិក្សា គេអាចកំណត់នូវគោលដៅអប់រំបានដូចជាៈ

១. <u>អប់រំសម្រាប់បណ្ដុះបញ្ញាញាណ</u>

មនុស្សជាច្រើនរូបបានគិតពិចារណាយ៉ាងយូរថា ការលើកកំពស់ការបណ្ដុះបញ្ញារបស់អ្នកសិក្សា គឺជាគោលដៅដ៏សំខាន់មួយរបស់សាលារៀន។

ជាការពិត ស្ទើរគ្មាននរណាម្នាក់ប្រឆាំងជំទាស់ចំពោះទស្សនៈថា អ្នកអប់រំត្រូវមានទំនួលខុសត្រូវចំពោះការអភិវឌ្ឍបញ្ញាញាណរបស់អ្នកសិក្សា។ លោក Robert Hutchins បានពោលថា "បើសិនការអប់រំបានផ្ដល់អោយចំណេះដឹងដ៏ត្រឹមត្រូវនោះវានឹងត្រូវបានគេយល់ថា ជាការសាបព្រួសនូវបញ្ញាញាណ"[៨] ។

ជាមួយគ្នានេះ ក៏មានការពិភាក្សាគ្នាមួយរវាងអ្នកអប់រំចំពោះការអភិវឌ្ឍបញ្ញានេះថា : ការពង្រីកវិសាលភាពនៃគោលដៅអប់រំចំណេះដឹង គឺវាមានសារសំខាន់ជាងអ្វីៗទាំងអស់។

កម្មវិធីសិក្សាក្នុងសាលារៀនត្រូវបានគេកែប្រែជាបន្តបន្ទាប់ ដើម្បីបណ្ដុះចំណេះដឹងដល់អ្នកសិក្សាទាំងឡាយ។ ក្នុងកម្មវិធីសិក្សា គេត្រូវបង្កប់នូវខ្លឹមសារដែលទាក់ទងជាមួយភូមិសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ សាសនា ទំនៀមទំលាប់ ជំនឿ ពោលគឺអ្វីៗដែលជាអត្តសញ្ញាណជាតិរបស់ខ្លួន និងបច្ចេកទេស វិទ្យាសាស្ត្រដែលកំពុងវិវត្តក្នុងសង្គមសព្វថ្ងៃនេះ។

ដូច្នេះ ក្រោយពីបានសិក្សាកម្មវិធីសិក្សាក្នុងសាលារៀនហើយ ពួកគេមានមោទនភាពស្រឡាញ់ខ្លួន បងប្អូន គ្រួសារ ជនរួមជាតិ និងទឹកដីមាតុភូមិ និងមរតកវប្បធម៌របស់ខ្លួន។

២. <u>ការអប់រំសំរាប់រៀបចំវិជ្ជាជីវៈ</u> (បុរេវិជ្ជាជីវៈ)

មនុស្សភាគច្រើនតែងតែមានជំនឿថា សាលារៀនជាអ្នកទទួលខុសត្រូវលើការរៀបចំយុវជនក្មេងៗអោយប្រឡូកក្នុងពិភពនៃការងារ។ អ្នកអប់រំ និងសាលារៀនជាអ្នកតម្រង់ទិសនៃការរៀបចំបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់អ្នកសិក្សាទាំងឡាយ អោយមានបំណិនឯកទេសជាក់លាក់បំផុតដែលជាក្ដីសង្ឃឹមរបស់យុវជន។ នៅពេលបញ្ចប់ពីសាលារៀនទៅ គេមានលទ្ធភាពងាយស្រួលក្នុងការជ្រើសរើសមុខរបរចិញ្ចឹមជីវិតបាន ហើយឪពុកម្ដាយរបស់សិស្សក៏មិនសោកស្ដាយថវិកាលើការវិនិយោគអប់រំនោះដែរ។

ជាទូទៅ បុគ្គលភាគច្រើនតែងតែចោទប្រកាន់សាលារៀនថា សេវាកម្មនៃការបណ្ដុះបណ្ដាលពុំទាន់មានលក្ខណៈគ្រប់គ្រាន់អោយឆ្លើយតបទៅនឹងតំរូវការសង្គមបានទេ ព្រោះនៅពេលដែលក្រុមហ៊ុនបានជ្រើសរើសយកយុវជនទាំងនោះទៅបំរើការងារ ប្រធានក្រុមហ៊ុនបានចំណាយពេលវេលា ថវិកា ដើម្បីបណ្ដុះបណ្ដាលបុគ្គលិកកម្មករទាំងនោះឡើងវិញ ទើបអាចចូលប្រឡូកបំរើការបាន។

ដូចនេះ ទាំងអ្នកអប់រំ ទាំងអ្នករៀបកម្មវិធីសិក្សា ត្រូវតែមានលក្ខណៈទន់ភ្លន់ជានិច្ច ក្នុងការបញ្ចូលនូវមុខវិជ្ជាបច្ចេកទេសដែលមានលក្ខណៈអនុវត្តក្នុងសង្គមសព្វថ្ងៃនេះ។

(នៅមានត) អនុបណ្ឌិត ស្វាយ សួគន

(៨) Cf. David G.Armstrong Education An Introduction, New York, 1989, p-8

# ការណែនាំវិធីគរុកោសល្យ (តចប់)

**គ_ការងារជាអ្នកឧទ្ទេស :**

មុននឹងឧទ្ទេសមេរៀន ត្រូវក្ដាប់ខ្លឹមសារបទឧទ្ទេសអោយបានច្បាស់លាស់។

- ពេលឡើងឧទ្ទេស ត្រូវចេះសំដែងការគួរសមចំពោះអង្គប្រជុំ និងអ្នកចូលរួមប្រជុំ។
- ត្រូវមានទឹកមុខរីករាយ មានប្រជាប្រិយភាព។
- ពេលឡើងឧទ្ទេស ត្រូវនិយាយបណ្ដើរ ឬសរសេរគំរោងលើក្ដារខៀន ឬល្បះសំខាន់ៗបណ្ដើរៗអោយសិក្ខាកាមបានកត់ត្រា និងងាយយល់បានស្រួលគ្រប់ៗគ្នា។
- ត្រូវចេះបង្កើតសំនួរ ដើម្បីអោយអ្នកចូលរួមបានត្រិះរិះពិចារណា និងឆ្លើយចំលើយល្អដែលធ្វើអោយអ្នកដែលមិនសូវយល់ឆាប់ចាប់បាន និងរៀនសូត្រពីគ្នាទៅវិញទៅមក ចៀសវាងនិយាយតែម្នាក់ឯងអោយសិក្ខាកាមអង្គុយចាំតែស្ដាប់គ្មានសកម្មភាព។
- ពេលនោះត្រូវធ្វើអោយអ្នកចូលរួម មានចំរុងប្រយ័ត្ន កុំអោយគេជជែកគ្នា បើមានការជជែកត្រូវបង្កើតពាក្យយ៉ាងណាអោយគេវិលអារម្មណ៍មករកយើងវិញ គឺធ្វើដូចម្ដេចអោយគេសកម្មចូលរួមតាមដាន។ បើមានសំភារៈ សំភារៈនោះត្រូវមានលក្ខណៈវិទ្យាសាស្ត្រ និងមានសោភណភាពដែលងាយមើលបានគ្រប់ៗគ្នា។
- ក្នុងពេលឧទ្ទេស ត្រូវចេះលើកឧទាហរណ៍ជាក់ស្ដែងយកមកបញ្ជាក់ ដើម្បីអោយខ្លឹមសារមេរៀននេះកាន់តែសុក្រឹតថែមទៀត។
- ជួនកាលការឧទ្ទេសនោះវែងធ្វើអោយបរិយាកាសខ្វះភាពរីករាយ គ្រូឧទ្ទេសត្រូវចេះធ្វើអោយបរិយាកាសសប្បាយរីករាយឡើងវិញ ដូចជាប្រើពាក្យកំប្លែង តែមិនឃ្លៀងពេកទេ រួចហើយទើបបន្តការរៀនសូត្រទៅទៀត។
- ត្រូវរក្សាឥរិយាបថ អាកប្បកិរិយាអោយបានថ្លៃថ្នូរ។
- ត្រូវជ្រើសរើសទីតាំងក្នុងការធ្វើឧទ្ទេសអោយបានសមស្របតាមកាលៈទេសៈ ដើម្បីធ្វើអោយការឧទ្ទេសមានប្រសិទ្ធភាព។
- ពេលឧទ្ទេស គ្រូឧទ្ទេសត្រូវមានសំលេងឮច្បាស់ៗល្អ ហើយចេះលើកដាក់សំលេងទៅតាមខ្លឹមសារនៃល្បះនីមួយៗ ហើយត្រូវចេះកាត់ជាកថាខ័ណ្ឌមួយៗអោយបានសមស្របតាមខ្លឹមសារមេរៀន។
- ពេលឧទ្ទេស ត្រូវរៀបចំគំនិតក្នុងខួរក្បាលជាបន្តបន្ទាប់ ដើម្បីអោយការឧទ្ទេសនេះមានលក្ខណៈជា

ប្រព័ន្ធដែលធ្វើអោយអ្នកស្តាប់ងាយស្តាប់ និងកត់ត្រាបានស្រួល ។

- ត្រូវចេះលំអិតតាមចំណុចជើងតូចៗនីមួយៗអោយបានច្បាស់លាស់ និងចេះពន្យល់ពាក្យណាដែលពិបាកយល់ និងចេះសង្កត់ខ្លាំងត្រង់ខ្លឹមសារណាដែលសំខាន់ៗ ។
- ត្រូវចេះដាក់សំនួរពិភាក្សាអោយបានសមស្របតាមខ្លឹមសារមេរៀនដែលបានបង្រៀន ។

ឃ_អ្នកណែនាំការពិភាក្សា

អ្នកណែនាំការពិភាក្សាក្រុមនីមួយៗត្រូវស្គាល់ និងយល់អំពីភារកិច្ចសំខាន់ៗ ដូចខាងក្រោម:

១-ភារកិច្ចរៀបចំ និងចាត់តាំង : អ្នកណែនាំក្រុមត្រូវ :

- ចេះគ្រប់គ្រងពេលវេលាអោយបានសមស្រប ។
- ចេះកំណត់ទីកន្លែងសំរាប់ធ្វើការពិភាក្សា និងចេះណែនាំអំពីរបៀបរបបនៃការប្រើប្រាស់សំភារឧទ្ទេសដែលបំរើដល់ការងារពិភាក្សា ។
- ចេះចលនាក្រុមអោយមានរបៀបរបបធ្វើការពិភាក្សាបានត្រឹមត្រូវ និងចេះចលនាប្រធានក្រុមពិភាក្សាអោយចេះចាត់តាំងកំលាំងចូលរួមពិភាក្សា និងចាត់តាំងលេខាកត់ត្រារបស់ក្រុមពិភាក្សា ។

២-ភារកិច្ចគ្រប់គ្រង : នេះជាភារកិច្ចមួយដែលសំខាន់ជាងគេបំផុត ព្រោះអ្នកណែនាំក្រុមពិភាក្សាត្រូវចេះគ្រប់គ្រងរាល់សកម្មភាពរបស់ក្រុមនៅក្នុងទិដ្ឋភាពផ្សេងៗគ្នា ។

- ការគ្រប់គ្រងទៅលើពេលវេលា និងចង្វាក់នៃការងារពិភាក្សាតាមក្រុម ។
- ការគ្រប់គ្រងទៅលើទំនាក់ទំនងរវាងអ្នកចូលរួមមានមតិពិភាក្សា និងការកើតកំណត់នៃការមានមតិយោបល់ ។
- ការគ្រប់គ្រងទៅលើការងាររវាងសមាជិកនៃក្រុមពិភាក្សាមួយ និងការងារនៃសមាជិកក្រុមពិភាក្សាផ្សេងៗ ។
- ការគ្រប់គ្រងទៅលើជំលោះ ឬមតិប្រាសចាកពីខ្លឹមសារនៃបទពិភាក្សារបស់ក្រុមដូចជា ការចូលចិត្តមានមតិពិភាក្សាឬបាច់វែងអន្លាយតែម្នាក់ឯង ការរាំងស្ទះដល់ដំណើរការពិភាក្សា ការបង្កភាពអសកម្មផ្សេងៗដែលធ្វើអោយការពិភាក្សារបស់ក្រុមមិនបានសំរេចតាមទិសដៅ ។

៣-ភារកិច្ចសំរួលការងារ :

- អ្នកណែនាំក្រុមត្រូវសំរួលនូវរាល់សកម្មភាពទាំងឡាយណាដែលនាំការពិភាក្សារបស់ក្រុមមានការរីកចំរើនជាក់ស្តែង ។
- ការសំរបសំរួលនូវមធ្យោបាយសំភារៈសំរាប់ដំណើរការពិភាក្សារបស់ក្រុម ។
- ការជួយផ្តល់មតិយោបល់ ឬព័តិមានផ្សេងៗក្នុងករណីដែលអ្នកណែនាំយល់ឃើញថា ចាំបាច់

ត្រូវបំផុសជំរុញការពិភាក្សារបស់ក្រុមអោយមានភាពផុសផុល ។

- ការជួយផ្តល់នូវសំភារៈបរិក្ខារឬវិធីសាស្ត្រនៃការងារពិភាក្សាក្នុងករណីដែលក្រុមត្រូវអសកម្ម ការងារដោយបញ្ហារបៀបរបបនៃការងារចាត់តាំងក្រុមឬការខ្វះខាតនូវសំភារបរិក្ខារចាំបាច់ ។

៤-ភារកិច្ចជាក់ស្តែង : អ្នកណែនាំក្រុមពិភាក្សា ÷

- ត្រូវចេះបង្ហាញអោយបានច្បាស់លាស់នូវគោលដៅ និងខ្លឹមសារនៃការពិភាក្សា ។ ទន្ទឹមនោះត្រូវចេះបង្ហាញនូវចំណុចគន្លឹះសំខាន់ៗសំរាប់ជ្រើសរើស ដើម្បីសំរេចគោលដៅ និងខ្លឹមសារទាំងនោះ ។
- ត្រូវចេះធ្វើអោយក្រុមពិភាក្សាយល់អំពីមុខងាររបស់គេម្នាក់ៗ ហើយនិងបែបផែននៃការទទួលខុសត្រូវ និងសំរេចមុខងាររបស់គេម្នាក់ៗ ។
- ត្រូវជួយផ្តល់មតិយោបល់ ជូនកាលក្នុងករណីដែលក្រុមពិភាក្សាកំពុងដំណើរការបានល្អ ហើយជាទូទៅត្រូវចេះរួមបំបែកមតិយោបល់ក្នុងករណីដែលមានបញ្ហាផ្សេងៗដែលកើតមានឡើងជាយថាហេតុក្នុងក្រុម ។

៥-ភារកិច្ចវាយតំលៃ : អ្នកណែនាំក្រុមពិភាក្សាត្រូវតែធ្វើការវាយតំលៃទៅលើរាល់លទ្ធផលនៃការពិភាក្សារបស់ក្រុម ។ ការវាយតំលៃនេះត្រូវផ្អែកលើមូលដ្ឋាននៃគោលដៅ ឬខ្លឹមសារនៃការពិភាក្សា ។

- ការវាយតំលៃនោះ គឺការវាយតំលៃអំពីគុណភាព ប៉ុន្តែមិនមែនជាគុណភាពរបស់ក្រុម "ល្អ ឬ អន់ថយ" នោះទេ តែជាគុណភាពនៃបែបបទដែលក្រុមពិភាក្សាបានធ្វើសកម្មភាពប្រៀបធៀបទៅនឹង "ការកំរិតកំណត់នៃការពិភាក្សា" ឬទៅនឹងគោលដៅដែលក្រុមបានសំរេច ឬមិនសំរេច ។

## III. វាយតំលៃ

បន្ទាប់ពីបានធ្វើការប្រជុំគរុកោសល្យ ឬសិក្ខាសាលារួចហើយ គ្រូឧទ្ទេសត្រូវធ្វើការវាយតំលៃទៅលើពីរចំណុចដូចតទៅ :

- រង្វាយតំលៃរបស់គណៈគ្រប់គ្រងវគ្គលើកំរិតចំណេះដឹង ចំណេះធ្វើ ការអនុវត្ត និងអាកប្បកិរិយា ផ្លូវចិត្តដែលសិក្ខាកាមបានទទួលតាមរយៈការធ្វើតេស្តនៃដំណាក់កាលនីមួយៗ កិច្ចធ្វើតេស្តត្រួតពិនិត្យបញ្ចប់វគ្គ ។
- រង្វាយតំលៃរបស់សិក្ខាកាម : លើសកម្មភាពប្រជុំ ឬសិក្ខាសាលាក្នុងដំណាក់កាលនីមួយៗ និងក្នុងវគ្គទាំងស្រុងដែលជាការផ្តល់ពត៌មានត្រឡប់បញ្ជាក់អំពីចំណុចពេញចិត្ត ចំណុចមិនទាន់ពេញចិត្ត និងសំណូមពរដើម្បីអោយគណៈគ្រប់គ្រងវគ្គមានមូលដ្ឋានកែលំអការរៀបចំដំណាក់កាលប្រជុំ ឬសិក្ខាសាលាបន្តបន្ទាប់ខាងក្រោមទៀត ។

ការវាយតំលៃលើការណែនាំគរុកោសល្យ ត្រូវផ្អែកលើមូលដ្ឋាន ៤ គឺ :

**១.ដំណើរប្រព្រឹត្តទៅនៃការប្រជុំ ឬសិក្ខាសាលា**

- ការកំណត់ទីកន្លែង និងពេលវេលាយ៉ាងណា?
- ការកសាងកម្មវិធី និងផែនការនៃការប្រជុំ ឬសិក្ខាសាលាត្រឹមត្រូវ ឬទេ?
- ការចូលរួមរបស់សិក្ខាកាមយ៉ាងដូចម្តេច?

**២.បទឧទ្ទេស**

- ការឧទ្ទេសបានក្បោះក្បាយច្បាស់លាស់ឬទេ?
- ការឧទ្ទេសធានាពេលវេលាត្រឹមត្រូវឬទេ?
- បទឧទ្ទេសរបស់វាគ្មិនម្នាក់ៗធានាខ្លឹមសារីកចំរើន ធានាប្រសិទ្ធភាពនៃការពិភាក្សាឬទេ?
- វាគ្មិនចេះបង្កបរិយាកាសរីករាយសប្បាយក្នុងការប្រជុំ ឬសិក្ខាសាលាឬទេ?
- បទអន្តរាគមន៍បានធ្វើឡើងត្រូវតាមទិសដៅឬទេ?
- ការផ្លាស់ប្តូរទស្សនៈ បទពិសោធន៍ស្តែងឡើងនូវស្មារតីប្រជាធិបតេយ្យឬទេ? (បែបបទនៃការប្រជុំតុមូល) ។

**៣.ការពិភាក្សារបស់ក្រុម**

- សមាជិកក្រុមចេះវិធីពិភាក្សាឬទេ? គេកំណត់បានទិសដៅនៃការពិភាក្សាឬទេ?
- ការចូលរួមពិភាក្សាបានល្អផុសផុលឬទេ?
- ប្រធានក្រុមពិភាក្សាជួយណែនាំដល់ក្រុមយ៉ាងដូចម្តេចខ្លះ?
- តើមានការផុសផុលមតិយោបល់ ដើម្បីស្វែងរកគោលដៅនៃការពិភាក្សាឬទេ?
- តើប្រធានក្រុមពិភាក្សាគ្រប់គ្រងការពិភាក្សាបានឬទេ?

**៤.លទ្ធផលនៃការប្រជុំ ឬសិក្ខាសាលា**

- ក្រោយពីបទឧទ្ទេស និងពិភាក្សាតាមក្រុម តើអ្នកចូលរួមប្រជុំ ឬសិក្ខាសាលាមានអ្វីប្លែកដែលជាចំណេះដឹងថ្មីឬទេ?
- តើការដាក់ចេញនូវទិសដៅ ឬសេចក្តីសំរេចរបស់អង្គប្រជុំ ឬសិក្ខាសាលាអាចមានប្រសិទ្ធភាពក្នុងការអនុវត្តនាពេលខាងមុខឬទេ?
- តើអ្នកចូលរួម ឬសមាជិកសហគមន៍ផ្សេងៗយល់ឃើញយ៉ាងណា ចំពោះលទ្ធផលនៃការប្រជុំ ឬសិក្ខាសាលាដែលបានប្រព្រឹត្តកន្លងមក? តើគេពេញចិត្តនឹងចូលរួមទៀតឬទេ?៕

**លោក ខេត សឿន**

ប្រធានការិ.អប់រំ និងគ្រប់គ្រង

នៃវិទ្យាស្ថានជាតិអប់រំ

# វិធីបង្រៀន និងកម្មវិធីសៀវភៅសិក្សាភាសាខ្មែរនៅ បឋមសិក្សាចំពេញវិជ្ជា ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧០(ត)

## ៣-វិធីបង្រៀនភាសាខ្មែរនៅថ្នាក់បឋមសិក្សាចំពេញវិជ្ជា

វិធីបង្រៀនភាសាខ្មែរនៅសម័យសង្គមរាស្ត្រនិយមបានវិវត្តទៅតាមដំណាក់កាលពីរ ដោយយោងទៅតាមការផ្លាស់ប្តូរកម្មវិធីសិក្សានៅក្នុងសម័យនោះ។ នៅមុនឆ្នាំ១៩៥៨ វិធីបង្រៀនភាសាខ្មែរបានអនុវត្តតាមកម្មវិធីបង្រៀននៅក្នុងសម័យអាណានិគមនិយមបារាំង។ នៅក្រោយឆ្នាំ១៩៥៨ វិធីបង្រៀនភាសាខ្មែរបានផ្លាស់ប្តូរ ដើម្បីអោយស្របទៅនឹងកម្មវិធីសិក្សាថ្មីនៃប្រទេសដែលមានឯករាជ្យ។

### ក-ការបង្រៀនអំណាន

#### ក.១-គោលបំណងនៃអំណាន

អំណានមានគោលបំណងធ្វើអោយសិស្សចេះអានបានត្រឹមត្រូវ រត់មាត់ មានលក្ខណៈរស់រវើក ចេះវាក្យសព្ទសម្បូរបែប យល់នៅពេលវាអាន ដោយបង្កើតបានគំនិតទូទៅ។ សិស្សអាចទាញយកប្រយោជន៍ពីអត្ថបទដែលវាអានទទួលបានចំណេះដឹងផ្សេងៗ។

#### ក.២-លក្ខណៈនៃអំណាន

អំណានមិនត្រូវមានលក្ខណៈរអាក់រអួល ទម្លាប់សិស្សអោយអានយឺតៗ មិនតក់ក្រហល់ មិនជាន់ពាក្យដែលក្នុងការអាន មិនដើរថយក្រោយ និងមិនស្ទាក់ស្ទើរ។ វាត្រូវអោយមានការបញ្ចេញសំលេងត្រឹមត្រូវ កុំបណ្តោយអោយសិស្សទាំងឡាយណាដែលមានអំណានខុសឆ្គង ។ បង្រៀនសិស្សអោយចេះលើកដាក់សំលេង អោយសិស្សអានពាក្យដោយមានការត្រួតពិនិត្យ។ អំណានត្រូវមានលក្ខណៈរស់រវើក ពោលគឺធ្វើយ៉ាងណាអោយអំណាននោះអាចសំដែងចេញបាននូវគំនិតពិតៗរបស់អ្នកនិពន្ធ។ អំណានត្រូវអោយមាន លក្ខណៈដែលសំរេចបានពិតប្រាកដ ដោយគោរពតាមវណ្ណយុត្តិ។ ការលើកដាក់សំលេងត្រូវខុសគ្នាទៅតាមគំនិតផ្សេងៗ ត្រូវគោរពតាមសម្ព័ន្ធឃ្លះដោយជៀសវាងសម្ព័ន្ធឃ្លះដែលមិនសមតាមបំណង។ ប៉ុន្តែចូរចាំថា វិធីបង្រៀនអំណានមួយដែលល្អ គឺជាវិធីមួយដែលធ្វើអោយសិស្សយល់ខ្លឹមសារអត្ថបទដោយគ្រាន់តែស្តាប់ដោយមិនចាំបាច់ផ្ទៀងផ្ទាត់អត្ថបទ។

#### ក.៣-ការជ្រើសរើសអត្ថបទ

អត្ថបទដែលត្រូវជ្រើសរើសដើម្បីបង្រៀនអោយសិស្សអាន ត្រូវមានលក្ខណៈដូចតទៅ : ជ្រើសរើសយកអត្ថបទដែលមានខ្លឹមសារសំខាន់ៗ ងាយយល់ ហើយមានអត្ថប្រយោជន៍ច្រើន។ អត្ថបទត្រូវអោយមានលក្ខណៈសំរបសំរួលបានទៅតាមកំរិតយល់ដឹងនៃសិស្សទាំងអស់ ត្រូវសំរួល និងលុបចោលនូវភាពលំបាកក្នុងអត្ថបទ។ អត្ថបទសំរួលទៅតាមមជ្ឈដ្ឋានរស់នៅ និងពេលវេលារបស់សិស្ស និងចំណង់ចំណូលចិត្តសិស្ស។

### ក.៤.ការរៀបចំកិច្ចតែងការបង្រៀន

ការរៀបចំកិច្ចតែងការបង្រៀន មានភាពចាំបាច់បំផុត ព្រោះការបង្រៀនរបស់គ្រូ មិនមែនសុទ្ធតែសំរេចបានតាមសំណូមពរនោះទេ ហើយវាអាចជៀសវាងបាននូវកំហុសដ៏ធ្ងន់ធ្ងរ ការបកស្រាយសើរៗ ឬទាំងដុលតែម្តង។ វាក៏ធ្វើអោយសិស្សយល់អត្ថបទកាន់តែច្បាស់ ហើយពន្យល់អត្ថបទនោះបានច្បាស់លាស់ផង។

ក្នុងកិច្ចតែងការបង្រៀននេះ គេត្រូវគ្រោងទុកនូវភាពលំបាក ចំណុចដែលត្រូវសង្កត់ធ្ងន់ (ការបន្លឺសំលេងសញ្ញាសម្ព័ន្ធ ការលើកដាក់សំលេង) ពាក្យ និងគំនិតដែលត្រូវលើកយកមកពន្យល់ សំណួរត្រូវចោទសួរសិស្ស អក្ខរាវិរុទ្ធ និងវេយ្យាករណ៍ សំភារៈដែលត្រូវយកមកប្រើប្រាស់ សកម្មភាពដែលត្រូវយកមកអនុវត្ត លំហាត់ដែលត្រូវដាក់អោយសិស្សធ្វើ។

### ក.៥.ការអនុវត្តវិធីបង្រៀនអំណាន

លោក ចេត្រ ឆែម អធិការបឋមសិក្សាបានណែនាំការបង្រៀននេះដោយតំរូវអោយគ្រូហ្វឹកហ្វឺនសិស្សអោយវាអានដូចជា វានិយាយទៅកាន់គូកនរបស់វា ដូចជាគេនិយាយគ្នាតាមធម្មតា។

ជាបឋម គ្រូត្រូវអានអត្ថបទមួយចប់ជាគំរូអោយសិស្សស្តាប់ តាមសេចក្តីរំលឹកខាងលើ បន្ទាប់មកអោយសិស្សអានមួយវគ្គម្តងៗ ព្រមទាំងពន្យល់ពាក្យណាដែលសិស្សមិនទាន់ស្គាល់ ដោយរកពាក្យណាដែលមានន័យប្រហែលគ្នា ឬដែលមានន័យផ្ទុយពីគ្នា ឬដោយយកគំនូរមកបង្ហាញ បើគ្មានវត្ថុបង្ហាញ ឬធ្វើសកម្មភាពអោយសិស្សមើល។ គ្រូអោយសិស្សអានអត្ថបទជាបុគ្គល និងជាក្រុម ព្រមទាំងសួរបញ្ជាក់សេចក្តីដែលគេអធិប្បាយ។ ចុងក្រោយបំផុតអោយសិស្សសង្ខេបអត្ថបទដែលទើបនឹងអានរួច ហើយអោយរកគោលសេចក្តីដែលគេអធិប្បាយ(១)។

នៅពាក់កណ្តាលទសវត្សឆ្នាំ១៩៦០ វិធីបង្រៀនភាសាខ្មែរត្រូវបានគេលំអិតជាច្រើនផ្នែកបន្តបន្ទាប់មកទៀត ដោយមានលំហាត់អានវាក្យសព្ទ ប្រកាសប្រាប់ពីចំណងជើងអត្ថបទ ក្នុងនោះមានកាលៈទេសៈនៃអត្ថបទ ទីកន្លែង ទឹកចិត្តរបស់អ្នកនិពន្ធ។

- គ្រូអានអត្ថបទជាគំរូអោយសិស្សអានតាម
- គ្រូបង្គាប់អោយសិស្សអានអត្ថបទដោយស្ងាត់ ដោយផ្ចង់ស្មារតីប្រុងប្រយ័ត្ន
- គ្រូហៅសិស្សអោយអានអត្ថបទម្តងម្នាក់ៗ តគ្នា សិស្សម្នាក់អានពី៤-៥បន្ទាត់
- ការពន្យល់ពាក្យ : ការពន្យល់ពាក្យនេះទាមទារអោយ :
    - ពន្យល់តាមន័យអត្ថានុរូប និងអត្ថបដិរូប
    - ភ្ជាប់ការពន្យល់ទៅនឹងគំនិតណែនាំរបស់អត្ថបទ
    - ធ្វើអោយមានភាពជាក់ស្តែងតាមការដែលអាចធ្វើទៅបាន
    - ត្រូវមានភាពច្បាស់លាស់ប្រាកដប្រជា

(១)សូមមើល ចេត្រ ឆែម :សេចក្តីណែនាំគ្រូបង្រៀននៅសាលាបឋមសិក្សា ភ្នំពេញ រោងពុម្ពហង្សរី ឆ្នាំ១៩៥៥ ទំព័រ៨

- អោយសិស្សអានអត្ថបទជាក្រុម
- សិក្សាគំនិតក្នុងអត្ថបទ
- ធ្វើគំរោងអត្ថបទ : ទំលាប់សិស្សអោយវែកញែកនូវផ្នែកផ្សេង១ខុស១គ្នា។ ចងក្រងគំនិតទៅតាមផ្នែកនីមួយ១ ដោយពាក្យ ឬកន្សោមពាក្យ
- ហៅសិស្សម្នាក់១អោយអានអត្ថបទ បន្ទាប់មកចោទសួរជាសំណួរត្រួតពិនិត្យលើពាក្យ ឬគំនិតនោះ
- សិក្សាអក្ខរាវិរុទ្ធ និងវេយ្យាករណ៍ :
  - ពាក្យបច្ចេកទេស (ការបំបែកពាក្យ ឬអត្ថន័យ)
  - សទិសសូរ សទិសន័យ ពាក្យផ្ទុយ វិភាគគំនិតសមហេតុផល ការបំបែកកិរិយាសព្ទតាមវេយ្យាករណ៍ ការសន្ទនា
- សង្ខេបអត្ថបទ :អាចធ្វើក៏បាន មិនធ្វើក៏បាន[១] ។

គេក៏បានណែនាំគ្រូអោយចងចាំថា បើសិនជាអត្ថបទនោះវែងពេក គ្រូត្រូវតែចែកជាពីរផ្នែក ឬអាចលែលកសិក្សាជាពីរពេល។ លើកទីមួយ ត្រូវសិក្សាវាក្យសព្ទ ហើយលើកទីពីរត្រូវសិក្សាពីគំនិតក្នុងអត្ថបទ។ ម្យ៉ាងវិញទៀត បើសិនជាអត្ថបទនោះ មានអត្ថន័យសមស្របល្អ គេត្រូវពង្រីកវាដោយមធ្យោបាយនៃការត្រួតពិនិត្យការយល់ដឹង លំហាត់ភាសា និងភាពស្ទាត់ជំនាញក្នុងភាសាអោយបានប្រសើរ ការអប់រំអត្តចរិតផងដែរ។ គេក៏អាចប្រើប្រាស់ការសំដែងជាអាយ៉ងតុក្កតាផងដែរ។

ទោះបីជាត្រូវការគន្លឹះច្រើនក្នុងការបង្រៀនមេរៀនអំណានមួយក៏ដោយ ក៏អំណាននៅតែជាមុខវិជ្ជាមួយដែលមានប្រយោជន៍បំផុត ក្នុងកម្មវិធីសិក្សា។ គ្រូត្រូវចេះប្រើប្រាស់វិធីបង្រៀនអំណានទៅតាមតំរូវការរបស់សិស្ស និងវិធីបង្រៀន។ ការបង្រៀនអំណានបានរួមចំណែកដល់វឌ្ឍនភាពនៃកិរិតយល់ដឹងរបស់សិស្សដ៏ឆាប់រហ័ស ហើយអាចជួយអោយសិស្សមានការរីកចំរើនបានគ្រប់មុខវិជ្ជាសិក្សាផ្សេងទៀត។

(នៅមានត)

អនុបណ្ឌិត ស្វ សុធីរ

---

(១)Cf.Ministère de l'Education Nationale, Cours de perfectionnement pédagogique, op. cit, p.53-54

# ការដឹកនាំសាលារៀន : ជំហានដំបូងមួយ(ត)

## នាយកសាលា និងគ្រូប្រចាំថ្នាក់

នាយកសាលាមានតួនាទីគន្លឹះក្នុងលំនាំអភិវឌ្ឍសាលារៀន។ ទំនាក់ទំនងល្អរវាងនាយកសាលា និងគ្រូប្រចាំថ្នាក់ គឺជាកត្តាសំរេចក្នុងការធ្វើអោយលំនាំនេះបានសំរេចប្រកបដោយប្រសិទ្ធភាព។

កន្លងមក នាយកសាលាខ្លះនិយមគ្រប់គ្រងសាលារបស់ខ្លួនតាមបែបអំណាច និងការបញ្ជា។ អស់លោកទាំងនោះ តែងប្រកាន់យកការធ្វើការសំរេចចិត្តដោយខ្លួនឯងលើគ្រប់ការងារទាំងអស់ រួចហើយបញ្ជាទៅថ្នាក់ក្រោមអោយអនុវត្ត។ ម្ល៉ោះហើយលោកគ្រូ-អ្នកគ្រូក្រោមឱវាទ ក៏មានឥរិយាបថអកម្ម និងពឹងផ្អែករង់ចាំតែបញ្ជា និងគ្មានគំនិតផ្ដើម។ ដោយហេតុនេះ នាយកសាលាក៏បាត់នូវឱកាសក្នុងការទទួលបាននូវមតិយោបល់ដ៏ល្អៗប្រកបដោយប្រសិទ្ធភាព ដែលខ្លួនគួរតែបានទទួលក្នុងការធ្វើអោយសាលារៀនមានការប្រែប្រួល។

នាយកសាលាដែលឈ្លាសវៃ រមែងបានទទួលជោគជ័យក្នុងការគ្រប់គ្រង ដោយគេមានយុទ្ធវិធីប្រមូលមតិយោបល់ និងកិច្ចជួយឧបត្ថម្ភពីគ្រប់អ្នកពាក់ព័ន្ធក្នុងសាលា ពិសេសគ្រូប្រចាំថ្នាក់ដែលជាសហការីដ៏ជិតបំផុត។ ជាទូទៅនៅប្រទេសកម្ពុជាយើង គ្រូប្រចាំថ្នាក់ច្រើនត្រូវបានដាក់អោយនៅដាច់ឆ្ងាយពីនាយក និងមិនសូវបានទទួលនូវការគោរព។ នេះជាបរិយាកាសមួយដែលមិនអនុគ្រោះអោយមានការរួមវិភាគទានជាគំនិតយោបល់ក្នុងការជួយទ្រទ្រង់សាលារៀនពីសំណាក់លោកគ្រូ-អ្នកគ្រូទេ ព្រោះថាពួកគេមានអារម្មណ៍ខ្លាច និងមិនមានទំនុកចិត្តក្នុងការបញ្ចេញយោបល់។ ដើម្បីអោយគ្រូបង្រៀនអាចហ៊ាននិយាយដោយសេរីជាមួយនាយករបស់ខ្លួនបាន នោះសាលារៀនត្រូវបង្កើតនូវបរិយាកាសមួយដែលគ្រូបង្រៀនមានអារម្មណ៍សុខដុម មិនខ្លាច និងមានទំនុកចិត្តផ្ទាល់ខ្លួន។

បរិយាកាសនេះ អាចត្រូវបង្កើតឡើងបាន លុះត្រាតែនាយកសាលាលើកកំពស់ភាពស្មោះត្រង់ជាមួយគ្នា ការទុកចិត្តគ្នា ការគោរពគ្នាទៅវិញទៅមក និងការយោគយល់គ្នា ហើយក្នុងករណីនេះនាយកសាលាត្រូវសំរបសំរួលឥរិយាបថរបស់ខ្លួនជាមួយនឹងមតិប្លែកៗប្រមូលផ្ដុំការរួមយោបល់ មិនបដិសេធការចូលរួម។

ម្យ៉ាងទៀត គប្បីយល់ថា គ្រូបង្រៀនមិនអាចផ្ដល់មតិយោបល់ប្រកបដោយប្រសិទ្ធភាពបានទេ ប្រសិនបើគ្មានភាពជាម្ចាស់ និងការទទួលខុសត្រូវ។ វិធីដ៏ល្អបំផុតដែលអាចជួយអោយគេទទួលបាននូវលក្ខណៈសម្បត្តិទាំងនេះ គឺធ្វើអោយគេបានរួមចំណែកក្នុងការដឹកនាំសាលារៀន ដោយបង្កលក្ខណៈអោយគេចូលរួមក្នុងការកំណត់ចក្ខុវិស័យសាលារៀន ការកំណត់ទិសដៅ ការធ្វើផែនការរបស់សាលារៀន និងរួមចំណែកក្នុងគ្រប់សកម្មភាពរបស់សាលា។ ពួកគេត្រូវតែមានសេរីភាព និងទំនុកចិត្តក្នុងការរួមវិភាគទានជាគំនិត និងសំណូមពរផ្សេងៗ។ គេត្រូវតែមានឱកាសរួមវិភាគទានក្នុងការរកដំណោះស្រាយនានា។

ដើម្បីអោយគ្រូបង្រៀនមានអារម្មណ៍សុខដុម និងមានទំនុកចិត្តក្នុងការរួមវិភាគទានជួយដោះស្រាយបញ្ហា

សាលារៀន នាយកសាលាត្រូវតែទុកចិត្តគេ។ កង្វះការទុកចិត្តមកលើខ្លួន បណ្តាលអោយមនុស្សម្នាក់ៗមានអារម្មណ៍ថាខ្លួនឯងអន់ មិនដល់គេ និងគ្មានទំនុកចិត្តលើខ្លួនឯង។ ប្រការនេះបណ្តាលអោយគេគ្មានអារម្មណ៍ទទួលខុសត្រូវ និងមានគំនិតពឹងផ្អែកក្នុងគ្រប់ដំណោះស្រាយនានា។ ជានិច្ចកាលគេមិនហ៊ានធ្វើការសំរេចផ្សេងៗ គ្មានទំនុកចិត្តក្នុងការបញ្ចេញយោបល់ ហើយរង់ចាំតែការណែនាំពីថ្នាក់លើ។ ស្ថានភាពនេះនាំទៅរកវដ្តមួយដូចខាងក្រោម :




វដ្តនេះទាមទារត្រូវអោយមានការបំបែកជាដាច់ខាត ហើយការបើកចំហអាចត្រូវចាប់ផ្តើមឡើងជាមួយនឹងការចាប់ផ្តើមមានការជឿទុកចិត្តរបស់លោកនាយកសាលាទៅលើមនុស្សទាំងអស់។ ជឿទុកចិត្តលើមនុស្សណាម្នាក់ គឺធ្វើអោយគេមានទំនុកចិត្តលើខ្លួនគេ និងមានស្មារតីទទួលខុសត្រូវ។ មានវិធីច្រើនដែលនាយកសាលាអាចបង្ហាញនូវការជឿទុកចិត្តរបស់ខ្លួនទៅលើគ្រូបង្រៀន។ គ្រូបង្រៀនភាគច្រើនមានមោទនភាពណាស់ កាលណាត្រូវបានផ្តល់ឱកាសអោយធ្វើការសំរេចចិត្ត។ ដូចនេះ នាយកសាលាគួរតែអនុញ្ញាតអោយគេមានឱកាសធ្វើការសំរេចលើបញ្ហាសំខាន់ខ្លះៗរបស់សាលារៀន។ លើសពីនេះទៀត ទំនុកចិត្តអាចកើតឡើងបានកាលណាគ្រូម្នាក់ៗត្រូវបានទទួលការយកចិត្តទុកដាក់ដោយស្មើៗគ្នា។ នាយកសាលាមួយចំនួនផ្តល់ទំនុកចិត្តតែទៅលើគ្រូម្នាក់ ឬពីរនាក់ដែលខ្លួនមើលឃើញថា មានសមត្ថភាពគ្រប់គ្រាន់ ហើយលើកទឹកចិត្តគ្រូនោះដោយផ្តល់អោយមានការទទួលខុសត្រូវលើភារកិច្ចបន្ថែមមួយចំនួន។ គ្រូម្នាក់ ឬពីរនាក់នោះ មានអារម្មណ៍ទទួលការជំរុញអោយមានការខំប្រឹងប្រែងនៅពេលដែលគ្រូភាគច្រើនដែលពុំមានឱកាសនឹងសាកល្បងមានអារម្មណ៍ថា ខ្លួនត្រូវបានបដិសេធអោយនៅក្រៅក្រុម ហើយបរិយាកាសនៃការបែងចែក ក៏ត្រូវបានបង្កើតឡើងក្នុងសាលារៀន។ នាយកសាលាល្អ ត្រូវយកចិត្តទុកដាក់ចំពោះគ្រូដោយស្មើៗគ្នា។ គ្រូម្នាក់ៗត្រូវតែមានឱកាសសាកល្បងនូវវិធីសាស្ត្រថ្មីៗ ហើយដោយការអនុវត្តបែបនេះ ពួកគេនឹងបានអភិវឌ្ឍនូវសមត្ថភាពវិភាគពិចារណារបស់គេ។ ប្រការនេះ អាចជួយអោយនាយកសាលាអាចនឹងបានទទួលថែមទៀតនូវការរួមចំណែកជាគំនិតថ្មីៗ និងដំណោះស្រាយបែបនវកម្មជាច្រើនទៀតផង។

វិធីដ៏ល្អមួយទៀតក្នុងការលើកកំពស់ទំនុកចិត្តលើខ្លួនឯង គឺនាយកសាលាត្រូវបើកចំហទទួលគំនិតថ្មីៗ និងផ្តល់ឱកាសអោយអ្នកឯទៀតមានគំនិតផ្តើម។ ប្រការដែលគួរអោយស្តាយ គឺថាប្រទេសកម្ពុជាយើងបានឆ្លងកាត់ក្នុងរយៈកាលដ៏យូរក្នុងប្រព័ន្ធឋានានុក្រមទាំងក្នុងគ្រួសារ ក៏ដូចជាក្នុងសង្គម។ ក្នុងគ្រួសារ កូនត្រូវតែស្តាប់បង្គាប់មាតាបិតា

ដែលខ្លួនគាត់ក៏ត្រូវតែស្តាប់មាតាបិតារបស់គាត់បន្តទៅទៀត ប្រសិនបើអ្នកទាំងនោះនៅរស់។ ក្នុងសង្គម អ្នកក្រោមឱវាទ ត្រូវតែស្តាប់ចៅហ្វាយនាយ សិស្សត្រូវតែស្តាប់គ្រូ។ គ្រប់ការណែនាំទាំងអស់ពីថ្នាក់លើ ត្រូវតែគោរពដោយពុំមានការពិភាក្សា។ គំនិតថ្មី គំនិតផ្តើម ឬនវកម្មមានឱកាសតិចតួចបំផុតត្រូវបានគេស្តាប់។ លើសពីនេះទៀត ដោយយើងបានឆ្លងកាត់អស់រយៈពេលយ៉ាងយូរក្នុងរបៀបធ្វើការបែបប្រព័ន្ធមជ្ឈការ នោះនាយកសាលាភាគច្រើនមានការលំបាកក្នុងការកែប្រែឥរិយាបថរបស់ខ្លួនទៅរកការបើកចំហ។ ដូចនេះ ពួកគេច្រើនតែមិនលើកទឹកចិត្តអោយមានការចូលរួម ហើយដោយហេតុនេះ គេក៏បាត់ឱកាសក្នុងការបានទទួលគំនិតថ្មីៗ និងគំនិតផ្តើមនានាដែលអាចបានជាថាមពលដ៏រឹងមាំក្នុងការជួយសាលារៀន។ នាយកសាលាល្អ ត្រូវចេះស្តាប់យោបល់របស់គេ ហើយទទួលយកនូវរិភាគទានរបស់គេដោយបើកចំហទទួលគំនិតថ្មីៗ ដើម្បីបើកឱកាសអោយគេមានគំនិតផ្តើម និងនវកម្មក្នុងដំណោះស្រាយ។ គេយកចិត្តទុកដាក់ចំពោះគ្រប់សំណូមពរពីសហការីរបស់គេ សាកល្បងវា និងស្វែងរកមេរៀនពីចំណុចខ្លាំង និងចំណុចខ្សោយរបស់វា។ ធ្វើបានយ៉ាងនេះ គេពិតជាកសាងបានក្នុងជួរគ្រូបង្រៀននូវស្វ័យទំនុកចិត្ត និងស្វ័យទទួលខុសត្រូវ ហើយគំនិតលើការកែលំអសាលារៀនក៏កាន់តែបានសំបូរបែប។

ទំនុកចិត្តដែលកសាងបានមកហើយអាចនឹងបាត់បង់ទៅវិញយ៉ាងងាយ ប្រសិនបើគ្រូបង្រៀនជួបនូវបរាជ័យក្នុងឱកាសដែលគេសាកល្បងដំបូង។ ដូចនេះ វាជាការសំខាន់ណាស់ដែលនាយកសាលាត្រូវរួមចំណែកទទួលខុសត្រូវចំពោះបរាជ័យរបស់គ្រូ។ ក្នុងករណីដែលមានបរាជ័យ នាយកសាលាគួរតែពិភាក្សាជាមួយគ្រូបង្រៀនពីការលំបាក និងដំណោះស្រាយជាជាងស្វែងរកថា តើជាកំហុសរបស់អ្នកណា។ ការស្ថាបនាលើចំណុចខ្លាំង ប្រសើរជាងការស្វែងរកចំណុចខ្សោយ។ គប្បីចាប់ផ្តើមពីការស្វែងយល់ពីចំណុចខ្លាំងរបស់លោកគ្រូ-អ្នកគ្រូ ជាជាងគិតរកតែចំណុចខ្វះខាតរបស់គេ។ ការធ្វើយ៉ាងនេះបាន លោកគ្រូ-អ្នកគ្រូនឹងមានមោទនភាពលើសមត្ថភាពរបស់គេ មានទំនុកចិត្តលើខ្លួនឯងកាន់តែច្រើន បង្កើនបាននូវស្មារតីជាម្ចាស់ និងភាពទទួលខុសត្រូវ ហើយដោយហេតុនេះ ការចូលរួមក្នុងការងារសាលារៀនក៏អាចប្រព្រឹត្តទៅដោយស្វ័យម្ភូត(១) ហើយតំរូវការរង់ចាំការណែនាំនឹងត្រូវប្រែទៅជាការពិភាក្សាដោយផុសផុល។ ទន្ទឹមនឹង ការរួមចំណែកទទួលខុសត្រូវលើបរាជ័យ ជាការសំខាន់នោះ ការឆ្លុះបញ្ចាំងជោគជ័យលើគ្រូបង្រៀនកាន់តែសំខាន់ថែមទៀត។ ជាញឹកញយ នាយកសាលាតែងប្រមូលយកជោគជ័យតែម្នាក់ឯង ហើយបង្ហាញនូវមោទនភាពខ្ពស់ដោយខ្លួនបានក្លាយជា "វីរជន" ក្នុងសាលាក្នុងពេលដែលគ្រូប្រចាំថ្នាក់ដែលបានខំប្រឹងប្រែងយ៉ាងលំបាកក្នុងការងារដែរនោះ មិនបានទទួលនូវការគិតដល់សោះ។ ប្រការនេះញ៉ាំងអោយគ្រូប្រចាំថ្នាក់រកាំចិត្ត និងមិនជំរុញអោយគេមានទឹកចិត្តយកចិត្តទុកដាក់ក្នុងការងារ។ គប្បីកំណត់ថា ប្រសិទ្ធភាពនៃសាលារៀន គឺជាលទ្ធផលរួមនៃសកម្មភាពនាយក និងគ្រូប្រចាំថ្នាក់។ គ្រូប្រចាំថ្នាក់គួរតែមានឱកាសបានសប្បាយនឹងជោគជ័យនៃការងារដែលគេបានបំពេញ។ ពួកគេពិតជាមានការជំរុញលើកទឹកចិត្តកាន់តែខ្ពស់ ប្រសិនបើគេមានអារម្មណ៍ថា គេមានការទទួលស្គាល់ពីមាតាបិតាសិស្ស សហគមន៍ និងសាធារណជន។

(១)ស្វ័យម្ភូត : ដែលកើតឯង. ស្វ័យម្ភូ (សយម្ភូ) : អ្នកកើតឯង។

**ទំនាក់ទំនង** ក៏ជាលក្ខណៈវិនិច្ឆ័យមួយសំរាប់ធ្វើអោយមានការចូលរួមពីសំណាក់គ្រូប្រចាំថ្នាក់ដែរ។ កន្លងមក នាយកសាលាភាគច្រើនតែងប្រកាន់យកការសំរេចចិត្តបែបពីលើទៅក្រោម។ គេទំលាប់ប្រាប់ទៅគ្រូនូវអ្វីដែលត្រូវធ្វើ ហើយមិនដែលអនុញ្ញាតអោយគ្រូមានឱកាសផ្ដល់យោបល់មកវិញទេ។ ពិតមែនហើយថា គេតែងបង្កអោយមានការប្រជុំជាមួយគ្រូ ប៉ុន្ដែនៅរាល់ការប្រជុំ លោកនាយករមែងលើកយកអនុសាសន៍របស់ខ្លួនទៅណែនាំអោយអនុវត្ត ហើយលោកគ្រូអ្នកគ្រូរវល់មមាញឹកក្នុងការកត់ត្រានូវមតិណែនាំនេះ មិនបានទទួលការលើកទឹកចិត្តអោយបញ្ចេញយោបល់ ឬរួមចំណែកក្នុងដំណោះស្រាយអ្វីទេ។បរិយាកាសនេះមិនបានលើកកំពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់ទេ ហើយពិតជានាំទៅរករបៀបដឹកនាំបែបផ្ដាច់ការ។ នាយកសាលាក្លាយជាអ្នកត្រួតត្រា ហើយលោកគ្រូ-អ្នកគ្រូជាសាវ័កដែលរង់ចាំតែទទួលបញ្ជា។ សំណូមពរល្អៗប្រកបដោយគំនិតផ្ដើមនវកម្ម និងប្រសិទ្ធភាពដែលនាយកសាលាគួរតែបានទទួលនោះក៏ត្រូវខាតបង់។ នាយកសាលាដែលប្រកបដោយប្រសិទ្ធភាពការងាររមែងប្រកាន់យកទំនាក់ទំនងបែបពីរទិស។ ទំនាក់ទំនងប្រភេទនេះ អាចកើតមានឡើងប្រកបដោយប្រសិទ្ធភាពនៅពេលណាមានការជជែកគ្នាពីការអនុវត្ត ការសង្កេតគ្នាទៅវិញទៅមក ការធ្វើផែនការរួមគ្នា ការបង្រៀនគ្នា និងអន្ដរសកម្មភាព។ម្យ៉ាងទៀត កាលណាទំនាក់ទំនងបែបនេះអាចកើតមានឡើងបាននោះ នាយកសាលានិងគ្រូបង្រៀនក៏ក្លាយជាសហសេវិកនឹងគ្នា។ ការបានក្លាយជាសហសេវិកនឹងគ្នា ធ្វើអោយមនុស្សជិតស្និទ្ធជាមួយគ្នា រាក់ទាក់រវាងគ្នានឹងគ្នា និងមិនសូវខ្លាចគ្នា។ ប្រការនេះ ញ៉ាំងអោយគ្រូបង្រៀនមានទំនុកចិត្តក្នុងការរួមចំណែកបញ្ចេញយោបល់ បង្ហាញបទពិសោធន៍ និងធ្វើសំណូមពរទាំងក្នុងការធ្វើផែនការក៏ដូចជាក្នុងការអនុវត្ត។ បរិយាកាសនៃការគ្រប់គ្រងក៏ក្លាយជាមានការសំរបសំរួលច្រើនជាងការបញ្ជា។

**ទំនាក់ទំនងបែបអន្ដរសកម្មភាព** អាចជួយអោយបង្កើតបាននូវគំនិតច្នៃប្រឌិតដែលជាលក្ខខណ្ឌចាំបាច់មួយសំរាប់ការអភិវឌ្ឍសាលារៀនអោយកាន់តែមានប្រសិទ្ធភាពខ្ពស់។ ដើម្បីលើកកំពស់អន្ដរសកម្មភាព នាយកសាលាគួរតែរៀបចំអោយមានពេលវេលាអង្គុយជជែកគ្នាជាមួយគ្រូបង្រៀន ទាំងជាផ្លូវការ ទាំងមិនផ្លូវការ។ គ្រូបង្រៀនគួរតែត្រូវបានលើកទឹកចិត្តអោយផ្ដល់យោបល់ អោយស្ដាប់យោបល់គ្នាទៅវិញទៅមកក្នុងឱកាសការប្រជុំពិភាក្សានានា។

ជាឧទាហរណ៍ វិធីទំនាក់ទំនងដែលនាយកសាលាគប្បីប្រកាន់យកគួរមាន ÷

- ការប្រជុំបុគ្គលិកជាទៀងទាត់។
- ក្ដារខៀនពត៌មានដែលបង្ហាញពីពត៌មានផ្សេងៗដូចជា គំនិតថ្មីដែលត្រូវបានសាកល្បងនៅក្នុងសាលា ពត៌មានពីទស្សនកិច្ចនានា សេចក្ដីណែនាំថ្មីៗពីក្រសួងអប់រំ ។ល។
- ប្រអប់ផ្ដល់យោបល់ដែលផ្ដល់ឱកាសអោយគ្រូអាចផ្ដល់មតិយោបល់បានក្នុងករណីដែលគេមិនចង់បង្ហាញឈ្មោះ។
- ការប្រជុំលើកកំពស់វិជ្ជាជីវៈតាមក្រុមរបស់គ្រូ។

វិធីមួយទៀត ដើម្បីបានទទួលជំនួយពីលោកគ្រូ-អ្នកគ្រូនោះ គឺការលើកទឹកចិត្តអោយគេធ្វើការជាក្រុម។ មកដល់បច្ចុប្បន្ននេះ នៅសាលារៀនភាគច្រើនគេធ្វើការជាបុគ្គលដាច់ដោយឡែកពីគ្នា។ ប្រការនេះ គឺជាការលើក

កំពស់គំនិតបុគ្គលនិយម ដែលកំរបានជួយសាលារៀនអោយបានប្រកបដោយប្រសិទ្ធភាពណាស់។ ដើម្បីលើកកំពស់បរិយាកាសស្និទ្ធស្នាល យល់គ្នា និងជួយគ្នាទៅវិញទៅមក នោះយើងត្រូវការចាំបាច់នូវការកសាងរបៀបធ្វើការជាក្រុម។ ការធ្វើការជាក្រុមអាចជួយអោយសមាជិកក្រុមម្នាក់ៗ :

- បានបង្កើនសមត្ថភាពរបស់ខ្លួនតាមរយៈការរំលែកបទពិសោធន៍គ្នាទៅវិញទៅមក
- ជួយទ្រទ្រង់គ្នាទៅវិញទៅមក និងមិនមានអារម្មណ៍ឯកោ
- ជួយគ្នាដោះស្រាយបញ្ហាទាន់ពេល
- រក្សាបាននូវការជំរុញទឹកចិត្ត។

ប៉ុន្តែដើម្បីបានជាក្រុមល្អ សមាជិកក្រុមម្នាក់ៗត្រូវគោរពនូវលក្ខណៈវិនិច្ឆ័យមួយចំនួនខាងក្រោម :

- ក្រុមត្រូវមានទិសដៅដែលត្រូវបានកសាងឡើងរួមគ្នា
- អ្នកដឹកនាំក្រុមត្រូវតែជាមនុស្សច្នៃប្រឌិត
- សមាជិកក្រុមត្រូវតែស្មោះត្រង់នឹងគ្នា និងជឿទុកចិត្តគ្នាទៅវិញទៅមក
- សមាជិកក្រុមត្រូវតែស្តាប់គ្នាទៅវិញទៅមក
- សមាជិកក្រុមត្រូវគោរពរាល់ផែនការ និងការសំរេចរបស់ក្រុម
- សមាជិកក្រុមត្រូវប្រព្រឹត្តចំពោះគ្នានឹងគ្នាដោយស្មើភាព ហើយត្រូវតែជិតដិត និងស្និទ្ធស្នាលរវាងគ្នានឹងគ្នា។

(នៅមានត)

ដោយលោក អ៊ុច សារិត
និវត្តជនខេត្តតាកែវ
អតីតអនុប្រធានមន្ទីរអ.យ.ក.

**ចំលើយប្រស្នាទំព័រទី ៩ :**

១- រមាស

២- X មាស ⇨ មាស

# ការបង្រៀនវិទ្យាសាស្ត្រនៅមត្តេយ្យសិក្សា និងបឋមសិក្សា

នៅដើមសតវត្សរ៍ទី២១នេះ វិទ្យាសាស្ត្រនិងគណិតវិទ្យាមានតួនាទីកាន់តែធំធេង និងមិនអាចខ្វះបានក្នុងជីវភាពរស់នៅសព្វថ្ងៃ។ សង្គមដែលមានការអភិវឌ្ឍមិនអាចរស់នៅបានដោយគ្មានវិទ្យាសាស្ត្រទេ។ ប្រឈមមុខនឹងបញ្ហានេះ ប្រទេសជាច្រើនបាននាំគ្នាពិនិត្យឡើងវិញលើការបង្រៀនមុខវិជ្ជាខ្លះក្នុងប្រព័ន្ធអប់រំ និងកែលំអឡើងវិញអំពីកម្មវិធីនៃការបង្រៀនវិទ្យាសាស្ត្រនៅសាលាបឋមសិក្សា។ ការបង្រៀនមុខវិជ្ជានេះ មានសារៈសំខាន់ណាស់សំរាប់ជួយជំរុញការបណ្តុះបណ្តាលកុមារតាំងពីគេនៅតូច ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់ប្រទេសជាតិទៅអនាគត។ ការអប់រំវិទ្យាសាស្ត្រអាចរីកចំរើនធំធេងបានអាស្រ័យទៅលើលំនាំនៃការបង្រៀន។ ប្រទេសជាច្រើនបានយល់ពីសារប្រយោជន៍នៃការបង្រៀនវិទ្យាសាស្ត្រតាមលក្ខណៈពិតរបស់ធម្មជាតិដែលជាសកម្មភាពមួយជួយជំរុញអោយកុមារកាន់តែយល់ពីផលប្រយោជន៍នៃមុខវិជ្ជានេះដោយធ្វើអោយកុមារចូលប្រឡូកដោយផ្ទាល់ដៃក្នុងដំណើរការស្វែងរកវិទ្យាសាស្ត្រដោយខ្លាប់ខ្លួនតាមលំនាំមួយដែលគេហៅថា "ការប្រឡូកដោយផ្ទាល់ដៃ"។ [១]

គំរោងការប្រឡូកដោយផ្ទាល់ដៃបានចូលទៅក្នុងគំរោងមួយដែលធ្វើអោយមានការរីកចំរើន និងការធ្វើអោយកាន់តែប្រសើរឡើងនូវការបង្រៀនវិទ្យាសាស្ត្រ។ លំនាំបង្រៀននេះ បានចាប់ផ្តើមអនុវត្តនៅប្រទេសបារាំងនៅឆ្នាំ ១៩៩៦ ក្រោមគំនិតផ្តួចផ្តើមរបស់លោកសាស្ត្រាចារ្យ George Charpak អ្នកប្រាជ្ញរូបវិទ្យាជនជាតិបារាំងដែលបានទទួលរង្វាន់ Nobel នៅឆ្នាំ ១៩៩២ ហើយបានត្រូវអនុវត្តក្នុងបណ្តាប្រទេសជាច្រើនក្នុងពិភពលោកមានជាអាទិ៍ ប្រទេសបារាំង ប្រទេសនានានៅអាមេរិកខាងត្បូង នៅទ្វីបអាហ្វ្រិក និងបណ្តាប្រទេសនៅអាស៊ី មាន ម៉ាឡេស៊ី វៀតណាម ចិន ។ល។

ការប្រឡូកដោយផ្ទាល់ដៃ ជាកម្មវិធីវិទ្យាសាស្ត្រសំរាប់បឋមសិក្សាក្នុងគោលបំណងជួយជំរុញ គ្រូបង្រៀនអោយដាក់កុមារក្នុងស្ថានភាពដែលអាចធ្វើពិសោធន៍ សង្កេត ចោទសំណួរ ត្រិះរិះពិចារណា អភិវឌ្ឍ ចំណេះដឹង និងអភិវឌ្ឍសមត្ថភាពវិទ្យាសាស្ត្រដែលមានក្នុងវត្ថុបំណង រឺជាបាតុភូតនៃពិភពលោកក្នុងបរិស្ថានជុំវិញ និងដែលកុមារអាចប៉ះពាល់ រឺអនុវត្តដោយវិញ្ញាណទាំង ៥ បាន។ វត្ថុបំណងមួយទៀត គឺដាក់កុមារអោយស្ថិតក្នុងស្ថានភាពជាអ្នកស្រាវជ្រាវវិទ្យាសាស្ត្រពិតប្រាកដ។ ការប្រឡូកដោយផ្ទាល់ដៃមិនមែនអភិវឌ្ឍត្រឹមតែសមត្ថភាពវិទ្យាសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែលំនាំបង្រៀននេះនាំកុមារអោយធ្វើអំណះអំណាងដោយផ្ទាល់មាត់ រឺដោយសរសេរ វាអាចពង្រឹងសំណេរ និងការនិយាយព្រមទាំងនាំកុមារអោយគោរពគំនិតយោបល់អ្នកដទៃដែលគេហៅថា ការអប់រំពលរដ្ឋវិជ្ជា។

(១) "La main à la pâte ឬ Hands-on"

នៅឆ្នាំ១៩៩៥ លោកសាស្ត្រាចារ្យ George Charpak បានដឹកនាំក្រុមការងាររបស់លោកទៅកាន់តំបន់ក្រីក្រមួយនៅជាយក្រុង Chicago សហរដ្ឋអាមេរិក។ នៅទីនោះ ក្នុងពេលសិក្សាវិទ្យាសាស្ត្រ សិស្សធ្វើការងារជាក្រុមកត់ត្រាលទ្ធផលរបស់គេក្នុងសៀវភៅ រៀនតាក់តែងកត់ត្រាពាក្យថ្មី ថែមទាំងជក់ចិត្តក្នុងការធ្វើពិសោធន៍មិនព្រមឈប់។

នៅឆ្នាំ ១៩៩៦ លោកក៏យកលំនាំនេះមកបង្ហាញដល់បណ្ឌិតសភាវិទ្យាសាស្ត្រនៅប្រទេសបារាំង បន្ទាប់មកក៏យកលំនាំមកធ្វើការពិសោធដោយដាក់ឈ្មោះ "ការប្រឡូកដោយផ្ទាល់ដៃ" ដែលមានដៃគូ ផ្សេងទៀតពីគ្រូបង្រៀន។

## **គោលបំណង នៃលំនាំនេះ**

ចាប់ពីឆ្នាំ២០០៣គោលវិធីនេះត្រូវបានបញ្ចូលជាផ្លូវការក្នុងកម្មវិធីសិក្សាហើយត្រូវអនុវត្តទូទាំងប្រទេសបារាំង។

ដោយឡែកនៅកម្ពុជាយើង ក៏ក្រសួងអប់រំ យុវជន និងកីឡា បានអនុញ្ញាតអោយប្រើប្រាស់ផងដែរ ចាប់ពីឆ្នាំ ២០០៣ តាមរយៈ AUF (Agence Universitaire de la Francophonie) រីឯគោលការណ៍សំខាន់ៗរបស់លំនាំនោះមាន ១០ រួមមានលំនាំគរុកោសល្យ ៦ និងដៃគូការងារ ៤÷

<u>លំនាំគរុកោសល្យ</u>

១- សិស្សពិនិត្យវត្ថុ ឬបាតុភូតពិតណាមួយដែលនៅជុំវិញខ្លួនគេ ដែលគេធ្លាប់ជួបប្រទះ និងស្គាល់បានដោយវិញ្ញាណទាំង ៥ ព្រមទាំងធ្វើពិសោធន៍លើវត្ថុ ឬបាតុភូតទាំងនេះ។

២- នៅពេលកំពុងធ្វើពិសោធន៍ សិស្សត្រូវរកអំណះអំណាងបង្ហាញហេតុផលរៀងៗខ្លួន និងសំយោគយកមតិតែមួយរួមគ្នា ឆ្លងតាមការពិភាក្សាលើគំនិត និងលទ្ធផលរបស់ពួកគេ។ ពេលនោះសិស្សកសាងចំណេះដឹងបានដោយខ្លួនឯង ពីព្រោះថាគ្រប់សកម្មភាពដែលធ្វើដោយដៃសុទ្ធសាធតែម្នាក់ឯងពុំគ្រប់គ្រាន់ទេ។

៣- សកម្មភាពទាំងឡាយណាដែលត្រូវដាក់អោយសិស្សធ្វើ ត្រូវរៀបចំជាដំណាក់ៗអោយស្របទៅតាមកម្មវិធីនៃកំរិតថ្នាក់នីមួយៗ។ សកម្មភាពនេះអាចបង្កើតស្វ័យភាពមួយចំណែកដ៏ធំដល់សិស្សក្នុងការអភិវឌ្ឍចំណេះដឹង។

៤- ប្រធានបទមួយត្រូវប្រើរយៈពេលពីរម៉ោងសិក្សាជាប់គ្នាយ៉ាងតិច ហើយអាចបន្តបង្រៀនជាច្រើនសប្តាហ៍ទៅមុខទៀត។ និរន្តរភាពនៃសកម្មភាពទាំងនោះ និងវិធីសាស្ត្រគរុកោសល្យត្រូវបានអនុវត្តជាបន្តបន្ទាប់រហូត ដល់ចប់ភូមិសិក្សា។

៥- សិស្សម្នាក់ៗត្រូវមានសៀវភៅមួយក្បាលសំរាប់កត់ត្រាការពិសោធ និងកត់ត្រាគំនិតគេផ្ទាល់។

៦- វត្ថុបំណងចំបងនៃការសិក្សាវិទ្យាសាស្ត្រ គឺសិស្សចេះផ្តល់សម្មតិកម្មឈានឡើងជាលំដាប់ទទួលបានចំណេះដឹងវិទ្យាសាស្ត្រ និងមានបំណិនក្នុងការកសាងតារាងគូសគំនូសតាង អានតារាង និងបកស្រាយការពិសោធដោយមានការពង្រឹងសមត្ថភាពក្នុងការសរសេរ និងនិយាយ ព្រមទាំងចេះធ្វើការងារ និងរស់នៅជាសមូហភាព។

<u>ដៃគូការងារ</u>

៧- សង្គមគ្រួសារ និងសហគមន៍ទាំងមូលត្រូវចូលរួមសហការ ទើបការងារទាំងឡាយអាចសំរេចជោគជ័យបានក្នុងថ្នាក់រៀន។

៨- អ្នកវិទ្យាសាស្ត្រនៅតាមមូលដ្ឋាននីមួយៗ (សាកលវិទ្យាល័យ អង្គការក្រៅរដ្ឋាភិបាល សាស្ត្រាចារ្យនៅវិទ្យាល័យ...) ត្រូវចូលរួមលើកកំពស់ការងារក្នុងថ្នាក់រៀន ដោយយកសមត្ថភាពរបស់គេមកប្រើប្រាស់ក្នុងការជួយសាលារៀន ជួយថ្នាក់រៀន។

៩- មហាវិទ្យាល័យគរុកោសល្យ នាយកដ្ឋាននានា សាលាគរុកោសល្យ ត្រូវផ្តល់បទពិសោធន៍ផ្សេងៗ និងបច្ចេកទេសគរុកោសល្យដល់គ្រូបង្រៀន។

១០- គ្រូបង្រៀនអាចទទួលបានតាមគេហទំព័រ http://www.inrp.fr/lamp និង http://eds24.free.fr នូវចំណេះដឹង និងពត៌មានផ្សេងៗសំរាប់យកមកប្រើប្រាស់ (គំនិត សកម្មភាព ចំលើយ សំណួរទាំងឡាយដែលបានចោទសួរ...)។ ម្យ៉ាងទៀត ពួកគាត់ក៏អាចចូលរួមសហប្រតិបត្តិការក្នុងការងារណាមួយដោយប្តូរយោបល់ ឬប្តូរបទពិសោធជាមួយសហសេវិក គ្រូឧទ្ទេស និងអ្នកវិទ្យាសាស្ត្រនានានៅក្រៅប្រទេសបានតាមរយៈគេហទំព័រនេះ។

ដូចនេះ ប្រសិនបើផ្អែកលើគោលការណ៍នេះ ការដឹកនាំថ្នាក់រៀនបែបសិស្សមជ្ឈមណ្ឌលនោះ នឹងមានប្រសិទ្ធភាព ព្រោះថាក្នុងគោលវិធីនេះ គ្រូគ្រាន់តែបង្កើតលក្ខខណ្ឌនៃសកម្មភាពបញ្ជាក់ស្តែងរបស់សិស្សានុសិស្សតែប៉ុណ្ណោះ៕

ប្រែសំរួលដោយ **ក្រុមអធិការបឋមសិក្សា**
**នៃវិទ្យាស្ថានជាតិអប់រំ**

"រើសដៃ ផ្អែផ្អែក"
"មនុស្សរើសដៃ បំពេញផ្ទៃមិនដែលខ្វះ
មាននេះខ្វះនោះខ្វះ ឯអ្នកខ្វះតែងមករក"

Enseigner les sciences à l'école maternelle et élémentaire: la main à la pâte
INRP: Guide de découverte 2000: Service des publications 29, rue d'Ulm 75230 Paris Codese 05

# សិក្សាសង្គម

## ចំណីអាហារ

- ថ្នាក់ទី ៤
- មេរៀនទី ២២ : ចំណីអាហារ
- សៀវភៅសិស្ស ទំព័រទី ២៤
- សៀវភៅគ្រូ ទំព័រទី៥៥_៥៦

**អត្ថបទជំនួយ :**

**I. ក្រុមអាហារ ៥ យ៉ាង :**

អាហារត្រូវបានចាត់ជា ៥ ក្រុម អាស្រ័យទៅតាមប្រភពរបស់វា :

១- ផ្លែឈើ និងបន្លែ : ផ្តត់ផ្គង់ជីវជាតិ ខនិជ និងរបបអាហារសំរាប់សរសៃ

២- សាច់ និងត្រី : ផ្គត់ផ្គង់ប្រូតេអ៊ីនសំរាប់ការលូតលាស់ និងកែលំអរាងកាយ និងផ្គត់ផ្គង់ជាតិដែកសំរាប់ឈាម

៣- នំបុ័ង និងធញ្ញជាតិ : ផ្គត់ផ្គង់ថាមពល សរសៃ ប្រូតេអ៊ីន និងជីវជាតិខនិជផ្សេងៗទៀត

៤- ខ្លាញ់ និងប្រេង : ផ្គត់ផ្គង់ជីវជាតិ A និងថាមពល

៥- ផលិតផលទឹកដោះគោ : ផ្គត់ផ្គង់កាល់ស្យូមសំរាប់ឆ្អឹង និងធ្មេញ ជីវជាតិ និងប្រូតេអ៊ីនខ្លះៗទៀត។

**II. តំរូវការអាហារប្រចាំថ្ងៃ**

១- ផ្លែឈើ និងបន្លែ : បួនភាគ :
- ១ បៃតងចាស់-លឿង ឬពណ៌ទឹកក្រូច (វីតាមីន A)
- ១ ក្រូច (វីតាមីន C)
- ២ មកពីផ្សេងៗទៀត

២- សាច់ និងត្រី : មួយភាគ : ជ្រើសរើសយកពីសាច់គោ-សាច់គោខ្ចី-ចៀម-សត្វចិញ្ចឹម( មាន់)-ស៊ុត រឺត្រី

៣- នំបុ័ង និងធញ្ញជាតិ : បួនភាគ : ជ្រើសរើសយកពីនំបុ័ង, ធញ្ញជាតិ, បាយ

៤- ខ្លាញ់ និងប្រេង :១ស្លាបព្រាបាយ : ជ្រើសរើសយកពីប៊ឺរ ខ្លាញ់ ទឹកដោះគោ ឬប្រេងឆា

៥- ផលិតផលទឹកដោះគោ : ៦០០ម.ល សំរាប់ក្មេង, ៣០០ម.ល សំរាប់មនុស្សចាស់។ ជ្រើសរើសយកពីក្រែមទឹកដោះគោជូ ឬហ្រ្វូម៉ាៗ

ប្រែសំរួលដោយ លោក កែវ យ៉ារ

Health and Fitness for the Primary School. Macmillan Black Line School. p.27

# គំនូរ

## វិធីបង្រៀនគំនូរ (ត)

ដោយលោក ប៉ាន់ គ្រា

### ការអោយស្រមោលវត្ថុមានរាងជ្រុង

**វត្ថុមានរាងជ្រុង**



រូបទី ១



រូបទី ២

១- វាស់ និងប្រមាណកំពស់ប្រអប់ដីស (រូបទី១) ។

២- យកខ្នាតវាស់កំពស់នោះមកវាស់ផ្ទួនទឹងបណ្តោយប្រអប់ ដើម្បីអោយដឹងថា បណ្តោយមានប៉ុន្មាន ខ្នាតទទឹង តាមភ្នែកមើលឃើញ (រូបទី២) ។

៣- គូសចតុកោណកែងមួយដែលមានបណ្តោយ និងទទឹងត្រឹមត្រូវតាមការវាស់ប្រមាណដែលបានធ្វើរួចមកហើយនៅលើផ្ទៃក្រដាស ។(រូបទី៣)



រូបទី ៣



រូបទី ៤



រូបទី ៥



រូបទី ៦



រូបទី ៧

៤- វាស់ និងប្រមាណទទឹងប្រអប់ (រូបទី៤) ។

៥- យកខ្នាតទទឹងនេះមកវាស់ប្រមាណនឹងបណ្តោយប្រអប់ ។ បណ្តោយ ប្រអប់មាន ៣ ដងទទឹង (រូបទី៥) ។

៦- នៅលើផ្ទៃក្រដាស វាស់ចេញពីទទឹងខាងឆ្វេង ១/៣ នៃបណ្តោយ ។

៧- ពិនិត្យសង្កេត និងប្រមាណអោយបានជាក់លាក់លើតំរូ ហើយគូរទទឹង នឹងគ្រប (រូបទី ៦ និង៧) ។

## ការអោយស្រមោលវត្ថុជ្រុង

ចំពោះវត្ថុដែលមានរាងជ្រុងវិញ ការអោយស្រមោលមានរបៀបប្លែកពីវត្ថុរាងមូល ។ ដូចនេះយើងជូនគំនូរ និងរបៀបផាត់ស្រមោលដូចខាងក្រោម ។

វត្ថុរាងជ្រុង ត្រូវមើលឃើញប្លែកៗគ្នាតាមទីកន្លែង និងទិសរបស់អ្នកមើល ។

### មើលពីឆ្វេង



ប្រអប់ដីស ឡាំង ទូរ៉ែត

## ការពិនិត្យសង្កេត

ចូរពិនិត្យមើលស្រមោលវត្ថុខាងលើទាំងអស់នេះ យើងនឹងឃើញថា ÷

- ជ្រុងដែលត្រូវពន្លឺចាំងមកចំ គឺជ្រុងទទឹងខាងឆ្វេងមានសំបុរភ្លឺ
- ជ្រុងបន្ទាប់ គឺជ្រុងចំហៀងខាងមុខ និងចំហៀងខាងក្រោយមានសំបុរខ្មៅព្រាល ។

### មើលពីស្តាំ




ចូរសង្កេតមើលស្រមោលវត្ថុខាងលើទាំងអស់នេះ យើងនឹងឃើញថា ÷

- ជ្រុងទទឹងខាងស្តាំដែលបាំងពន្លឺថ្ងៃត្រូវមានសំបុរខ្មៅ ជាងជ្រុងខាងមុខបន្តិច ។

ជ្រុងទទឹងខាងស្តាំដែលត្រូវបាំងពន្លឺនោះ មានសំបុរចាស់ជាងជ្រុងខាងមុខ និងខាងក្រោយ ។

ដូចនេះឃើញថា វត្ថុរាងជ្រុងនេះ ជ្រុងនីមួយៗមានស្រមោលខ្ចី ឬចាស់ខុសគ្នា ហើយដាច់ៗពីគ្នាទៀតផង មិនដូចវត្ថុដែលមានរាងមូលនោះឡើយ ។

នៅថ្នាក់ទី ៤ នេះ គំនូរគូរតាមគំហើញជារបៀបគូរមួយបែបដែលសិស្សត្រូវប្រើកត្តាទាំង៣ គឺពិនិត្យសង្កេត និងប្រមាណជាការចាំបាច់បំផុត ។

បើកត្តាទាំង ៣ នេះ មិនត្រូវបានយកមកអនុវត្តអោយបានច្បាស់លាស់ទេនោះ សិស្សប្រាកដជាពុំអាចនឹងគូររូបភាពវត្ថុទាំងឡាយនោះបានត្រឹមត្រូវឡើយ ។

ដូចនេះ លោកគ្រូ អ្នកគ្រូត្រូវយកចិត្តទុកដាក់ណែនាំសិស្សអោយចេះប្រើកត្តាទាំង ៣ នេះ ដើម្បីសំគាល់រូបរាង និងវាស់ប្រមាណទទឹង បណ្តោយ និងកំពស់វត្ថុទាំងឡាយដែលត្រូវគូរអោយបានពិតប្រាកដ ។

ហេតុនេះ ចំពោះលោកគ្រូ អ្នកគ្រូ ត្រូវមានការព្យាយាម និងអំណត់ក្នុងការដឹកនាំសិស្សអោយចេះវាស់ ចេះប្រមាណ ហើយចេះយកខ្នាតនោះមកគូសខ្មៅប្រឌិតលើផ្ទៃក្រដាសដូចយើងបានពន្យល់ និងបានគូរជាឧទាហរណ៍រួចមកហើយពីខាងលើស្រាប់ ។

ហេតុនេះ សុំលោកគ្រូ អ្នកគ្រូ ចាត់អោយសិស្សគូរគំនូររបៀបនេះអោយបានច្រើនដោយជ្រើសរើសជាគំនូរចាប់តាំងពីរបស់ងាយៗដែលសិស្សធ្លាប់បានឃើញ បានស្គាល់ឡើងទៅ ។

វត្ថុជាគំរូនេះ នឹងមានកំរិតកាន់តែពិបាកបន្តិចម្តងៗ កាលណាលោកគ្រូ អ្នកគ្រូ យល់ច្បាស់ថា សិស្សចេះយកកត្តាទាំង ៣ នោះមកអនុវត្ត និងចេះគូរខ្មៅជាគំនូរសំគាល់វត្ថុផ្សេងៗនោះនៅលើផ្ទៃក្រដាសបានត្រឹមត្រូវហើយ ។

( នៅមានត )

### តើមានអ្វីកើតឡើងក្នុងរយៈពេលមួយម៉ោងនៅលើពិភពលោកយើងនេះ?

| | | |
|---|---|---|
| ១_ចំនួនប្រជាជនកើនឡើង | ៩ ៣០០ | នាក់ |
| ២_បេះដូងរបស់មនុស្សលោតបាន | ៤ ៨០០ | ដង |
| ៣_សក់របស់មនុស្សលូតបាន | ០,១៨៧៩៦ | ម.ម |
| ៤_ប្រទេសស្កុតឡែនផលិតវីស្គីបាន | ១៧ ៤៦៥ | ដប |
| ៥_សំបុត្រផ្ញើទៅកាន់គ្រប់ទីកន្លែងចំនួន | ១ ៤២៦ ៩៤០ | សំបុត្រ |
| ៦_វិមានប៉ង់តាហ្គោនទទួលទូរស័ព្ទហៅចូលចំនួន | ៨ ៣០០ | លើក |
| ៧_ប្រទេសអាល្លឺម៉ង់ផលិតរថយន្តម៉ាក Wolkswagen បាន | ១៦៦ | គ្រឿង |
| ៨_កូកាកូឡាត្រូវបានមនុស្សផឹកអស់ចំនួន | ១ ២៥៤ ០០០ | កំប៉ុងឬដប |

អួន ស៊ីឡុត

Headway Intermediate-Oxford University Press 2000

# ភាសា

## ព្យាង្គតំរួតក្នុងសម័យខេមរយានកម្ម

អង្គការខេមរយានកម្ម បានបង្កើតឡើងនៅឆ្នាំ១៩៦៧ ដោយក្រសួងអប់រំជាតិចេញលិខិតបង្គាប់ការលេខ៥០៦កន. ចុះថ្ងៃទី០៥-០៨-៦៧ បង្កើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្មសិក្សា(១) ។ ក្រសួងអប់រំជាតិបានសំរេចទុកសម្ដេចព្រះសង្ឃរាជ និងសម្ដេចព្រះពោធិវង្សជាកំពូលក្នុងការអារកាត់រឿងសព្វសារពើដែលទាក់ទងនឹងខេមរយានកម្ម(២) ។

យើងចែករបៀបសរសេរពាក្យខេមរយានកម្មជា ២ ដំណាក់គឺ ÷

- ដំណាក់ទី១ ចាប់ពីឆ្នាំ១៩៦៧ ដល់ ១៩៧២
- ដំណាក់ទី២ ចាប់ពីឆ្នាំ ១៩៧២ ដល់ ១៩៧៥ ។

ដំណាក់ទី១ អង្គការខេមរយានកម្មពុំទាន់អាចញែកបានរវាងសំនេរព្យាង្គតំរួត និងសំនេរព្យាង្គរាយនៅឡើយទេ ។ តែក្រោយពេលសិក្សាស្រាវជ្រាវអស់រយៈកាលប្រមាណ ៣ ឆ្នាំមក ក្នុងដំណាក់ទី២ អង្គការខេមរយានកម្មបានញែកអោយឃើញច្បាស់នូវព្រំដែនរវាងសំនេរព្យាង្គតំរួត និងសំនេរព្យាង្គរាយ ។

តើខេមរយានកម្ម កំនត់យកក្បួនវិធីសរសេរព្យាង្គតំរួតដូចម្ដេច?

ក្នុងភាសាខ្មែរ ពាក្យពីរព្យាង្គអាចសរសេរជាព្យាង្គតំរួតក៏មាន សរសេរជាព្យាង្គរាយក៏មាន ÷

- ព្យាង្គរាយ គឺជាព្យាង្គដែលគេត្រូវសរសេរបន្តគ្នា ពោលគឺគេសរសេរព្យាង្គទី១ រួចហើយទើបគេសរសេរព្យាង្គទី២ បន្តពីព្យាង្គទី១នោះ ។
- ព្យាង្គតំរួត គឺជាព្យាង្គដែលគេត្រូវសរសេរតំរួតគ្នា ពោលគឺគេសរសេរព្យាង្គទី១រួចទើបគេសរសេរព្យាង្គទី២បន្ត ដោយសរសេរតំរួតព្យញ្ជនៈត្រង់តំនព្យាង្គទាំងពីរនោះ ។ តួព្យញ្ជនៈចុងព្យាង្គទី១នៅពីខាងលើតួព្យញ្ជនៈដើមព្យាង្គទី២នៅពីខាងក្រោម ។ តួព្យញ្ជនៈតំរួតបែបនេះពុំមែនជាតួព្យញ្ជនៈផ្សំនៅដើមព្យាង្គទេ ។

ឧទាហរណ៍ : ក្រើន : "ក្រ" ជាតួព្យញ្ជនៈតំរួតកត់សូរផ្សំនៅដើមព្យាង្គ ។

បង្កើន : "ង្ក" ជាតួព្យញ្ជនៈតំរួតក្នុងព្យាង្គតំរួតពុំមានកត់សូរផ្សំនៅដើមព្យាង្គឡើយ ។

### ១-ក្បួនវិធីផ្សេងៗក្នុងសម័យមុនដំណាក់ទី២នៃខេមរយានកម្ម

### ១.១ក្បួនវិធីសរសេរព្យាង្គតំរួត រឺក្បួនវិធីតំរួតព្យាង្គ

យើងអាចចែកក្បួនវិធីតំរួតព្យាង្គជា ៣ ប្រភេទ ÷

#### ១.១.១ប្រភេទទី១ : សៀវភៅវចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧

ក្នុងនិទាននៃវចនានុក្រមខ្មែរនៅទំព័រ "គ" មានសេចក្ដីថា ÷

(១) ស្ថានភាពខេមរយានកម្មនៅមធ្យមសិក្សាឆ្នាំ១៩៧២ ។

(២) ទស្សនាវដ្ដីខេមរយានកម្មក្នុងការសិក្សាឆ្នាំទី១ លេខ១ ឆ្នាំ១៩៦៧ ទំព័រ៤ ។

"ខ១១-កិរិយាសព្ទ ឬគុណសព្ទទោល គឺមានអក្សរមិនតំរួត ឬមិនត្រវាត់ មិនធ្វើជើងដល់ចេញមកជានាមសព្ទត្រូវប្រើភាយតួ ដូចជា កត់ កិ. > កំណត់ ន., កាត់ កិ. > កំណាត់ ន., ដឹង កិ. > ដំណឹង ន., ដើរ កិ. > ដំណើរ ន., តូច គុ. > តំណូច ន., ទាប គុ. > ទំនាប ន... ។ល។

ខ១២-កិរិយាសព្ទ ឬគុណសព្ទដែលមានអក្សរតំរួត ឬធ្វើជើង ត្រវាត់ដល់ចេញមកជានាមសព្ទត្រូវតំរួតដូចជា ក្រង កិ. > កម្រង ន., ក្រាស់ គុ. > កម្រាស់ ន... ។ល។ ប៉ុន្តែសព្ទខ្លះដែលតំរួតពុំកើតក៏មានដូចជា ភ្លឺ កិ.(កត្តុ.) > បំភ្លឺ កិ.(ហេតុ.), ផ្អើល កិ.(កត្តុ.) > បំផ្អើល កិ.(ហេតុ.), ឃ្លាត កិ.(កត្តុ.) > បង់ឃ្លាត កិ.(ហេតុ.)... ។"

<u>កំណត់សំគាល់</u> : នៅក្នុងសៀវភៅភាសាខ្មែររបស់លោក អៀវ កើស(១៩៦៧) ទំព័រ១៨៥ មានសេចក្ដីសង្កេតថា... ពាក្យក្លាយពីរជាន់ដូចជា កម្ចាត់ កម្សៀវ កម្ទេច... កើតឡើងដោយអាស្រ័យពាក្យក្លាយមួយជាន់ ខ្ចាត់ ខ្សៀវ ខ្ទេច ផ្សំនឹងផ្នត់ដែក "អន់" ។

**១.១.២ប្រភេទទី២មានសៀវភៅ**

- វេយ្យាករណ៍ខ្មែររបស់លោកសាស្ត្រាចារ្យ ពូវ អ៊ុយ (១៩៤៤)
- សំយោគវិធានរបស់ព្រះបាឡាត់ ឧត្តមលិខិត សុង ស៊ីវ សិទ្ធត្ថោ (១៩៥២)
- នវវេយ្យាករណ៍ និងខេមរភាសារបស់លោក សៀន ខ័នឌី និងលោក ព្រហ្ម ស៊ុនណារ៉េត (១៩៥៧)
- វេយ្យាការណ៍ពិសេសរបស់បណ្ឌិត អ៊ុយ ជូន (១៩៥៨)
- វេយ្យាការណ៍ខ្មែររបស់អ្នកឧកញ៉ាមហាមន្ត្រី ញ៉ុក ធូវ (១៩៥៩)ជាដើម ។

សូមលើកយកក្បួនវិធីតំរួតព្យាង្គក្នុងសៀវភៅវេយ្យាករណ៍ពិសេសរបស់លោកបណ្ឌិត អ៊ុយ ជូន មកបង្ហាញ ។

នៅទំព័រ៥២-៥៦ មានសេចក្ដីថា ព្យញ្ជនៈដែលតំរួតគ្នា...ហៅថា "ព្យញ្ជនៈសំយោគ" អក្សរតំរួតគ្នានេះច្រើនតែជាអក្សរប្រកបរបស់ពាក្យខាងដើម និងពាក្យខាងចុងដែលនៅក្នុងវគ្គជាមួយគ្នា...ឧទាហរណ៍ ដូចមានខាងក្រោមនេះ ÷

- **វគ្គទី១ (ក ខ គ ឃ ង)**

ក តំរួតលើ ក និង ខ ដូចជា សក្ការៈ សិក្ខាបទ...

គ តំរួតលើ គ និង ឃ ដូចជា អគ្គទូត អគ្ឃ...

ង តំរួតលើ ក ខ គ ឃ ង ដូចជា សង្កថា សង្ខារ សង្គម សង្ឃិក... ។

- **វគ្គទី២ (ច ឆ ជ ឈ ញ)**

ច តំរួតលើ ច និង ឆ ដូចជា សច្ចា តិរច្ឆាន...

ជ តំរួតលើ ជ និង ឈ ដូចជា មជ្ជារ មជ្ឈិម...

ញ តំរួតលើ ច ឆ ជ ឈ និង ញ ដូចជា សញ្ចារ កញ្ឆែត បញ្ជូន បញ្ឈរ កញ្ញា... ។

- **វគ្គទី៣ (ដ ឋ ឌ ឍ ណ)**

ដ តំរួតលើ ដ និង ឋ ដូចជា វដ្ដទុក្ខ គេហដ្ឋាន...

ឌ តំរួតលើ ឌ និង ឍ ដូចជា តិរោកុឌ្ឌសូត្រ វឌ្ឍនភាព...

ណ តំរួតលើ ដ ឋ ឌ ឍ និង ណ ដូចជា សណ្ដង់ សណ្ឋាន សណ្ឌាស ឈុណ្ឌិ ប៉ុណ្ណេះ...។

- **វគ្គទី ៤ (ត ថ ទ ធ ន)**

ត តំរួតលើ ត និង ថ ដូចជា អត្តលេខ អត្ថន័យ...

ទ តំរួតលើ ទ និង ធ ដូចជា សទ្ធវាចា ពុទ្ធង្កូរ...

ន តំរួតលើ ត ថ ទ ធ និង ន ដូចជា បន្ត បន្ថយ បន្ទើរ បន្ធូរ និន្នាទ...។

- **វគ្គទី ៥ (ប ផ ព ភ ម)**

ប តំរួតលើ ប និង ផ ដូចជា កប្បាស បុប្ផជាតិ...

ព តំរួតលើ ព និង ភ ដូចជា នព្វន្ត អព្ភូតហេតុ...

ម តំរួតលើ ប ផ ព ភ និង ម ដូចជា សម្បូរ សម្ផស្ស សម្ពោធ សម្ភោរ សម្មាសម្ពុទ្ធស្ស...។

ឯការតំរួតព្យញ្ជនៈក្នុងខេមរភាសាសុទ្ធ មិនមានវិធីតំរួតអោយទៀងទាត់តាមលំដាប់វគ្គពេកទេ...។ ឃើញមានច្រើនតែតំរួតជាមួយព្យញ្ជនៈទី៥ នៃវគ្គ... ដូចឧទាហរណ៍ខាងក្រោមនេះ ÷

- វគ្គទី១ : ង តំរួតលើ ក ខ គ ឃ ដូចជា សង្កែ សង្ខុញ សង្គ្រុប សង្ឃឹម...។
- វគ្គទី២ : ញ តំរួតលើ ច ឆ ជ ឈ ដូចជា បញ្ចប់ បញ្ឆោត បញ្ជា បញ្ឈប់...។
- វគ្គទី៣ : ណ តំរួតលើ ដ ឋ ឌ ឍ ដូចជា សណ្ដ សណ្ឋិត ឥណ្ឌូ ឈុណ្ឌិ...។
- វគ្គទី៤ : ន តំរួតលើ ត ថ ទ ធ ដូចជា កន្តុប កន្ថិក កន្ទក់ កន្ធា...។
- វគ្គទី៥ : ម តំរួតលើ ប ផ ព ភ ដូចជា ដម្បូក កម្ផិត សម្ពោធ សម្ភេទ...។

នៅទំព័រ៥៦-៥៧ មានសេចក្ដីថា

- ឃើញតំរួតលើ "អក្សរទីបំផុតវគ្គ"ដែរ... ដូចជាចម្ងាយ ប៉ុន្មាន សម្មាញ...។
- ព្យញ្ជនៈសេសវគ្គគឺ យ រ ល វ ស ហ អ អាចត្រួតជាមួយព្យញ្ជនៈវគ្គណា១ក៏បាន... ដូចជា កន្លាស់ កន្សែង កម្រង សង្វាត កម្លោះ កម្សត់ កម្ហល់ កម្អិត កម្អួត...។
- ប៉ុន្តែព្យញ្ជនៈសេសវគ្គទាំងនេះ មិនអាចតំរួតលើតួឯងបានឡើយ លើកតែ យ ល ស... ដូចជា សេយ្យាសន៍ បល្ល័ង្ក វស្សា...។

***<u>កំណត់សំគាល់:</u>***

១) -នៅក្នុងសៀវភៅវេយ្យាករណ៍ពិសេសទំព័រ៤៦ មានកំនត់បញ្ជាក់ថា មានពាក្យពីរព្យាង្គខ្លះទៀតអាចសរសេរតំរួតគ្នាដោយការផ្លាស់និគ្គហិត (ំ)ជា"ម" ក៏បាន សរសេរវាយតួក៏បាន តាមតែបំនងចិត្តរបស់ខ្លួនដែលនឹកឃើញ... ពាក្យទាំងនោះមានច្រើនអនេក ដូចឧទាហរណ៍ខាងក្រោមនេះ

ដំបាញ វឺដម្បាញ　　កំរ វឺកម្រ　　តំរា វឺតម្រា

ដំងី វឺដម្ងី　　កំបុត វឺ កម្បុត　　កំណាត់ វឺកម្ណាត់...។

២) -នៅក្នុងសៀវភៅសំយោគវិធាន ទំព័រ៣៣ មានកំណត់សំគាល់ថា "ម"នេះ ទោះបីតំរួតលើព្យញ្ជនៈណាក៏

ដោយ បើជាពាក្យខ្មែរសុទ្ធ សម័យឥឡូវច្រើននិយមសរសេររាយតួដូចជាកម្បាក់ > កំបាក់។

**១.១.៣ប្រភេទទី៣ : សៀវភៅវេយ្យាករណ៍ខ្មែរសង្ខេប "ស្វ័រសន្ទខ្មែរ" របស់លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ បោះពុម្ពឆ្នាំ១៩៦៦**

នៅទំព័រ ៩៨-១០០ មានសេចក្ដីថា

**ក្បួនតំរួតព្យាង្គបាលីសំស្ក្រឹត ÷**

- ព្យញ្ជនៈទី១ ត្រួតបានពីលើខ្លួនឯង និងពីលើព្យញ្ជនៈទី២ : ក្ក ច្ច ដ្ដ ត្ត ប្ប ក្ខ ច្ឆ ដ្ឋ ត្ថ ប្ផ
- ព្យញ្ជនៈទី៣ ត្រួតបានពីលើខ្លួនឯង និងពីលើព្យញ្ជនៈទី៤ : គ្គ ជ្ជ ឌ្ឌ ទ្ទ ព្ព គ្ឃ ជ្ឈ ឌ្ឍ ទ្ធ ព្ភ
- ព្យញ្ជនៈទី៥ ត្រួតបានពីលើខ្លួនឯង និងពីលើព្យញ្ជនៈទី១ ទី២ ទី៣ ទី៤ លើកលែងតែ "ង" : ង្ក ង្ខ ង្គ ង្ឃ ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ ណ្ដ ណ្ឋ ណ្ឌ ណ្ឍ ណ្ណ ន្ត ន្ថ ន្ទ ន្ធ ន្ន ម្ប ម្ផ ម្ព ម្ភ ម្ម។
- ព្យញ្ជនៈ យ ល ស អាចត្រួតលើខ្លួនឯង : យ្យ ល្ល ស្ស។

**ក្បួនតំរួតព្យាង្គខ្មែរ ÷**

តួត្រួតលើ : មានតែខ្យល់ច្រមុះ ង ញ ន ម... គ្មាន ណ ទេ។

ង : ង្ក ង្ខ ង្គ ង្ឃ ង្ក្រ ង្គ្រ ង្រ ង្វ ង្ហ

ញ : ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ច្រ ញ្ជ្រ

ណ : ខ្មែរគ្មាន

ន : ន្ត ន្ថ ន្ទ ន្ធ ន្ត្រ ន្ទ្រ ន្យ ន្វ ន្ស

ម : ម អាចត្រួតលើព្យញ្ជនៈវគ្គជាមួយគ្នា វីវគ្គខុសគ្នា...។ ...គេច្រើនយកសញ្ញាដំលើ ( ំ ) មកសរសេរជំនួសតួ ម ត្រួតលើក្នុងព្យញ្ជនៈតំរួត...។

តួត្រួតលើ ខ្លួនឯងពុំបានទេ។

តួត្រួតលើ ត្រួតលើខ្យល់ច្រមុះឯទៀតបាន

ម : ម្ង ម្ញ ម្ន

ន : ន្ម ។...

(នៅមានត)

លោក សូ មួយឃៀង

បទអន្តរាគមន៍នៅក្នុងសន្និសីទជាតិស្តីពីការស្រាវជ្រាវឯកសារ និងអភិវឌ្ឍន៍ភាសាខ្មែរលើកទី២ : ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០០៥ នៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា។




## គ្រូត្រូវតែល្អ ក្រត្រូវតែស៊ូ

គរុពាក្យខ្មែរប្រែថាធ្ងន់ គយគន់មើលយូរគួរខ្លាសអៀន
បើនាមប្រែថាគ្រូបង្រៀន ថ្លៃថ្នូរដោយគ្មានអ្វីមកប្រៀប ។
សីលធម៌ គុណធម៌មានគ្រប់យ៉ាង មិនកោងមិនកាងអាងសុភាព
រម្យទមរាក់ទាក់បន្ទន់ទាប មិនខ្ពស់មិនទាបភាពសប្បុរស ។
គ្រូល្អនៅត្រង់ក្រចេះស៊ូ ក្រមិនរអ៊ូ ស៊ូទាំងអស់
វិជ្ជាខ្ពង់ខ្ពស់ល្អឥតខ្ចោះ ស្រឡាញ់ស្ម័គ្រស្មោះស្មើៗគ្នា ។
គ្រូជាគំរូបង្ហាញផ្លូវ នាំអ្នកល្ងង់ទៅផុតអវិជ្ជា
រួចផុតទុក្ខសោកភ័យវេរា ដល់ត្រើយគ្រប់គ្នាលែងចំបែង ។
គ្រូល្អនៅត្រង់ចេះមានព្រហ្ម វិហារជាធំគ្រប់កន្លែង
ស្គាល់បាបគុណទោស ប្រាកដស្ដែង លែលកចែកបែងអហឹង្សា ។
សិទ្ធិមនុស្សប្រជាធិបតេយ្យ កាន់កាប់ក្នុងដៃគ្រប់មាត្រា
នីតិវិធីយន្ដការ ដោះស្រាយបញ្ហាដោយសុចរិត ។
គ្រូជាមេជាងដ៏ចំណាន អាចធ្វើអោយបានល្អវិចិត្រ
វត្ថុទាំងដុលកំរោលពិត កាប់ ចាំង ឈូស សិត ប្រណិតបាន ។
គ្រូល្អត្រូវតែមានឧត្ដម គតិជាធំក្នុងសណ្ដាន
ជួយអ្នករងគ្រោះទាំងប៉ុន្មាន មកជាកល្យាណមិត្តប្រពៃ ។
គ្រូល្អត្រូវមានធម៌សន្ដោស មេត្តាលើកទោសគ្រាប្រណី
មិនផ្ដួចផ្ដើមរឿងចេះអភ័យ អត់អោនខន្តីឧបេក្ខា ។
អ្នកប្រាជ្ញបូរាណចងក្រងទុក ទំនុកដំណែលពីដូនតា
បើជនណាកែស្រីពេស្យា អោយមកធម្មតាថាបណ្ឌិត ។
យ៉ាងណាមិញលោកគ្រូបង្រៀន ត្រូវចេះទូន្មានអ្នកល្ងង់ល្ងិត
បណ្ដុះបណ្ដាលចិត្តគំនិត បំភ្លឺជីវិតផុតទុក្ខភ័យ ៕

លោក ឈាន ថេង

# ដបស្បៃមិនជ្រាបទឹក

១-គេអោយដបកទូលាយមួយ និងស្បៃរំរបូស។ ចូរអ្នកយកស្បៃពីរជាន់ទៅពាសគ្របមាត់ដង រួចចងអោយជាប់នឹងកដបដោយខ្សែកៅស៊ូ ។



២-ចូរបញ្ចូលទឹកក្នុងដបដោយ បង្ហូរតាមរូបភាព។ ទឹក ហូរចូលដបដោយគ្មាន ទើសទាល់អ្វីទាំងអស់។



៣-ចូរផ្កាប់ដបគ្មានអ្វីហូរចេញទេ។ ក្នុងករណីនេះ ស្បៃបានបង្កើតការទប់ទឹកមិនអោយទឹកជ្រាបបាន ថ្វីត្បិតតំរងមានរន្ធក៏ដោយ ។



Science et Vie Junior

**ហេតុអ្វីដបនេះមិនជ្រាបទឹក?**

- លោកគ្រូ អ្នកគ្រូអាចរកមធ្យោបាយពន្យល់តាមការយល់ដឹង ឬបទពិសោធផ្ទាល់ខ្លួន
- លោកគ្រូ អ្នកគ្រូ អាចធ្វើការបកប្រែអត្ថបទភាសាបារាំងជាប់មកនេះ។

**Tout s'explique**

L'eau qui entre sans difficulté dans la bouteille ne peut en sortir. Pourtant, la gaze est bien évidemment symétrique. La retourner ne changerait rien au resultat de l'expérience. C'est donc l'eau qui fait la différence. Pour entrer dans la bouteille, elle jaillit du robinet où elle était maintenue sous pression et arrive sur le film de gaze avec une énergie importante. Pour sortir, l'eau est au contraire simplement posée sur le film avec, comme seule force d'entrainement, celle liée à son poids. Refaites cette même expérience en laissant entrer peu d'eau dans la bouteille (2 ou 3cm). Une fois la bouteille retournée, secouez-la violemment. L'eau qui se trouvait bloquée à l'intérieur sort à chaque impulsion.

Cela n'explique pas comment un film aussi troué qu'une passoire peut, dans certaines conditions, être aussi étanche que le meilleur des bouchons. La raison s'appelle "la tension superficielle". Replacez votre bouteille à l'endroit et déposez délicatement une goutte d'eau sur la gaze. Elle reste en place sans pouvoir traverser le filtre (voir dessin ci-dessus). Pour traverser le filtre, la goutte se déforme. Comme les mailles de la gaze sont serrées, la partie de la goutte qui sort en dessous a un rayon de courbure plus petit. C'est là qu'intervient la "tension superficielle". D'une manière générale, lorsque la surface d'un liquide est courbée, cela se traduit par une augmentation de la pression dans le liquide. Les forces correspondantes sont exercées vers l'intérieur du liquide, perpendiculairement à la surface. Elles sont d'autant plus importantes que le rayon de courbure est petit. La courbure étant plus importante dans la partie inférieure de la goutte, la force résultante est dirigée vers le haut. Cette force est suffisante pour contrecarrer l'effet de son poids. La goutte reste donc bloquée.




En secouant la bouteille, vous fournissez à la goutte une énergie sous la forme de mouvement. Vous l'aidez à passer la barrière. De la même manière, l'eau qui coule du robinet est suffisamment rapide pour traverser la piège.

Alain Schuhl

ទំព័រស្ត្រី

# យេនឌ័រ និងសន្តិសុខស្បៀង

ហួរ ស៊ី

សន្តិសុខស្បៀង ជាបញ្ហាដ៏ចំបងមួយនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នានាស្តីអំពីសន្តិសុខស្បៀងនៅក្នុងប្រទេស បានបង្ហាញនូវសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង។ នាពេលថ្មីៗនេះ អង្ករអតិរេក [១] បានកើនឡើង ក៏ប៉ុន្តែគ្រួសារនៅទីជនបទជាច្រើនហាក់បីដូចជាពុំមានលទ្ធភាព ឬក៏អាចទទួលបាន នូវការផ្គត់ផ្គង់ស្បៀងអាហារគ្រប់គ្រាន់តាមតំរូវការឡើយ [២]។ ២ភាគ៣ នៃប្រជាពលរដ្ឋ១.៦លានគ្រួសារដែលរស់នៅទីជនបទ ជួបប្រទះអសន្តិសុខស្បៀងតាមរដូវកាលក្នុងឆ្នាំនីមួយៗ។ មិនតែប៉ុណ្ណោះ ៥០ភាគរយនៃកុមារអាយុក្រោម៥ឆ្នាំ មានទំងន់មិនគ្រប់តាមកំរិតនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS)។

គ្រួសារនៅទីជនបទភាគច្រើន នៅពឹងពាក់អាស្រ័យលើទ្រព្យសម្បត្តិ ដីធ្លីកសិកម្ម និងធនធានធម្មជាតិនៅក្បែរភូមិដ្ឋានរបស់ខ្លួន។ ទ្រព្យសម្បត្តិ ដីធ្លីកសិកម្ម និងធនធានធម្មជាតិ គឺជាប្រភពប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់គ្រួសារក្រីក្រនៅតាមទីជនបទ ក៏ប៉ុន្តែគ្រួសារទាំងនោះកាន់កាប់ដីធ្លីតូចៗ [៣] ដែលមិនសមល្មមទៅនឹងការចិញ្ចឹមជីវិតបានឡើយ។ ម្យ៉ាងវិញទៀត ប្រភពធនធានធម្មជាតិមួយចំនួនត្រូវបានរដ្ឋផ្ទេរអោយទៅជាឯកជនអស់ទៅហើយ។ ដូច្នេះ គ្រួសារក្រីក្រទូទៅ អាចជួបប្រទះអសន្តិសុខស្បៀងពី៣ ទៅ៨ខែ ក្នុងមួយឆ្នាំ ព្រមទាំងមានជំពាក់បំណុលគេច្រើន និងគ្មានលទ្ធភាពសងត្រឡប់គេវិញបានឡើយ (ADB 2001)។

នៅឆ្នាំ២០០៤ កម្ពុជាប្រឈមមុខនឹងគ្រោះរាំងស្ងួតស្ទើរទូទៅទូទាំងតំបន់ពេញមួយឆ្នាំ។ ដីប្រកបរបរកសិកម្មជាច្រើនសែនហិកតាទទួលរងការខូចខាតដែលមានប្រជាពលរដ្ឋច្រើនសែន និងច្រើនលាននាក់ អាចនឹងប្រឈមមុខគ្រោះខ្វះស្បៀងអាហារនាឆ្នាំខាងមុខ [៤]។ តាមរបាយការណ៍របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ មានតំបន់ជាច្រើននៅតែទទួលទឹកភ្លៀងតិចតួច ដែលមិនអាចប្រកបមុខរបរកសិកម្មបាន។ របាយការណ៍ពីគណៈកម្មាធិការដដែលនេះ បានអះអាងថា នៅដំណាច់ខែសីហា បើសិនណាពុំមានទឹកភ្លៀងគ្រប់គ្រាន់ទេនោះ អាចនឹងមានដីប្រកបរបរកសិកម្មជាច្រើនពាន់ហិកតា ពុំមានលទ្ធភាពដកស្ទូងបាន និងប្រជាពលរដ្ឋតាមការប៉ាន់ស្មានរបស់ស្ថាប័ននេះ ប្រមាណ២លាននាក់អាចនឹងប្រឈមមុខនឹងគ្រោះអសន្តិសុខស្បៀងនាឆ្នាំក្រោយ។

បញ្ហាអស់ទាំងនេះ យើងអង្កេតឃើញថា ក្រុមស្ត្រី ហាក់បីដូចជាប្រឈមមុខច្រើនជាងគេ។ នៅប្រទេស

(១) ច្រើនក្រៃ ដែលហួសពីចំនួន. ចំនួនលើស

(២) Extracted from Final Draft "Rural Strategy towards Rural Area in Cambodia"15 February 2005

(៣) Average household of land tenure is 1,5 ha and about half of Cambodian household is less 0,75ha (CSES 1999)

(៤) Interviewed with H.E Nhim Vanda by Radio Free Asia and released on Sunday 17 July 2005

កម្ពុជាស្ត្រីមានភាគចំណែកច្រើនជាងបុរសប្រមាណ ៥២[៥] ភាគរយនៃកំលាំងពលកម្មសរុប។ របាយការណ៍ធនាគារអភិវឌ្ឍន៍អាស៊ីចេញផ្សាយឆ្នាំ២០០០ បានអះអាងថា ស្ត្រីកម្ពុជាមានភាគចំណែកនៅក្នុងវិស័យកសិកម្មប្រមាណ៧៨ ភាគរយ រីឯបុរសមានតែ៦៩ភាគរយប៉ុណ្ណោះ។ ដូចនេះ អសន្តិសុខស្បៀងនៅទីជនបទ ក្រុមស្ត្រីទំនងជាមានទំហំធំជាងបុរសយោងលើភាគចំណែកខាងលើនេះ។

